មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
# (១៩៧៥-១៩៧៩)

## *របាយការណ៍សម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ*
## *ថ្ងៃទី២៩ ខែមិថុនា ដល់ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩*
## *បណ្ណាល័យព្រឹទ្ធសភា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា*

*កិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយក្រសួងអប់រំយុវជននិងកីឡា*

### ១) សេចក្តីសង្ខេប

មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រាប់ថ្នាក់មធ្យមសិក្សា ជូនដល់មន្ត្រីកម្ពុជាចំនួន២៨រូប មកពីនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធី វិទ្យាស្ថានជាតិអប់រំ នាយកដ្ឋានអប់រំចំណេះដឹងទូទៅ និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ ។ វគ្គបណ្តុះបណ្តាលនេះក៏ផ្តល់ជូនដល់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៨រូបផងដែរ ។ សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ បានមកជួបជុំគ្នានៅបណ្ណាល័យព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញ ។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្នុងរយៈពេល៧ថ្ងៃ គឺពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ។ ការរៀបចំវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីផ្តល់ការអប់រំគរុកោសល្យទៅលើវិធីសាស្ត្រសម្រាប់បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនៃប្រទេសកម្ពុជា ដោយប្រើប្រាស់សៀវភៅរបស់លោក ឌី ខាំបូលី *"ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ(១៩៧៥-១៩៧៩)"* ។ ក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល លោក ឌី ខាំបូលី និងលោកសាស្ត្រាចារ្យ ដេវីដ ឆេនល័រ បានឆ្លើយបទបង្ហាញលើគ្រប់ជំពូកទាំងអស់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ។ នៅខណៈពេលនោះដែរ លោក គ្រីស ឌៀរីង និងបណ្ឌិត ជា ផល្លា បានធ្វើបទបង្ហាញទៅលើសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដែលជាសៀវភៅសម្រាប់អមជាមួយនឹងសៀវភៅប្រវត្តិសាស្ត្រ ។ ខ្សែភាពយន្ត ចម្រៀង ដំណើរទស្សនកិច្ច ព្រមទាំងបទបង្ហាញរបស់វាគ្មិន ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលនេះដែរ ។

វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិនេះ គឺជាជំហានទី១ នៅក្នុងដំណើរការបើកវគ្គបណ្តុះបណ្តាលគ្រូប្រវត្តិវិទ្យា គ្រូអក្សរសាស្ត្រខ្មែរ និងគ្រូសីលធម៌ពលរដ្ឋនៅទូទាំងប្រទេស ដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានការបណ្តុះបណ្តាលពីសំណាក់អ្នកជំនាញជាតិនិងអន្តរជាតិ សិក្ខាកាមទាំងអស់ទទួលបាននូវចំណេះដឹងជ្រៅជ្រះ ដើម្បីក្លាយខ្លួនទៅជាគ្រូខ្ទេសថ្នាក់ជាតិនៅក្នុងវគ្គបណ្តុះបណ្តាលបន្តបន្ទាប់ទៀត ។

របាយការណ៍ខាងក្រោមរៀបរាប់លម្អិតអំពីសកម្មភាពផ្សេងៗ ដែលកើតមានឡើងនៅក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ។ របាយការណ៍នេះក៏បានបង្ហាញផងដែរអំពីគោលបំណងនៃវគ្គបណ្តុះបណ្តាល ភាពខ្លាំង និងឧបសគ្គ ដែលបានជួបប្រទះក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិនេះ ។

## ២) រចនាសម្ព័ន្ធនៃគម្រោង

កម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាល ត្រូវបានតាក់តែងឡើងជុំវិញសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ (១៩៧៥-១៩៧៩) ដែលបោះពុម្ពឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅប្រវត្តិសាស្ត្រនេះ ត្រូវបានអនុម័តយល់ព្រមដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ប្រើប្រាស់ជាឯកសារគោលនៅតាមសាលារៀនក្នុងប្រទេសកម្ពុជា ។ សៀវភៅសិក្សានេះ ទទួលបានការអបអរសាទរពីសំណាក់សាធារណជននៅក្នុងប្រទេស និងនៅលើពិភពលោក ហើយជាសៀវភៅទីមួយដែលពណ៌នាប្រកបដោយភាពពិតឥតលម្អៀងអំពីព្រឹត្តិការណ៍និងបរិបថនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ដើម្បីជួយក្នុងការប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រនេះនៅក្នុងថ្នាក់រៀន បណ្ឌិត ជា ផល្លា និង លោក គ្រីស ឌៀរីង បាននិពន្ធសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្សដើម្បីអមជាមួយសៀវភៅប្រវត្តិសាស្ត្រ ។

ដំណាក់កាលបន្ទាប់ គ្រូបង្គោលថ្នាក់ជាតិទាំង២៨រូប និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាំង១៨រូប នឹងចូលរួមជួយបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨៦រូប ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៦ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ បន្ទាប់មក នៅក្នុងខែធ្នូ ឆ្នាំ២០០៩ គ្រូបង្គោលថ្នាក់ជាតិ និងគ្រូបង្គោលថ្នាក់ខេត្ត នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនជាង៣០០០រូបទៀតនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។ វិធីសាស្ត្រក្នុងការបណ្តុះបណ្តាលជាដំណាក់ៗនេះ ផ្តល់ឱកាសឲ្យជនជាតិកម្ពុជាបណ្តុះបណ្តាលគ្នាទៅវិញទៅមក ។ ធ្វើដូច្នេះប្រជាជនកម្ពុជាមានភាពជាម្ចាស់និងមានការទទួលខុសត្រូវទៅលើប្រវត្តិសាស្ត្រផ្ទាល់របស់ខ្លួន ។

## ៣) ការរំពឹងទុក

ការរំពឹងរបស់គម្រោងនេះមានបីយ៉ាងគឺ ៖ ទី១ យើងសង្ឃឹមថា គ្រូបង្គោលថ្នាក់ជាតិនឹងទទួលបានការយល់ដឹងច្បាស់លាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ។ ទី២ យើងសង្ឃឹមថា គ្រូបង្គោលថ្នាក់ជាតិនឹងអាចប្រើប្រាស់គោលការណ៍គរុកោសល្យឲ្យបានត្រឹមត្រូវ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀននៅវគ្គបន្ទាប់ និងជាចុងក្រោយផ្តល់ការអប់រំទៅដល់សិស្ស ។ ជាទីបញ្ចប់ យើងសង្ឃឹមថា គ្រូបង្គោល

ថ្នាក់ជាតិនឹងយល់ដឹងអំពីសារៈសំខាន់នៃការអប់រំពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា និងមានលទ្ធភាពក្នុងការគិតពីផលប៉ះពាល់នៃការអប់រំនេះ មកលើសង្គមនាពេលបច្ចុប្បន្ន ។ ខាងក្រោមនេះ គឺជាវត្ថុបំណង ដែលបានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងអប់រំយុវជននិងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់គម្រោងនៃការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទាំងមូល ៈ

១- ណែនាំសៀវភៅប្រវត្តិសាស្ត្ររបស់លោក ឌី ខាំបូលី សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស តាមសាលារៀនចាប់ពីថ្នាក់ទី៩ ដល់ថ្នាក់ទី១២ ។

២- បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ដល់គ្រូជាង៣០០០នាក់ ដែលជាគ្រូប្រវត្តិវិទ្យា, គ្រូអក្សរសាស្ត្រខ្មែរ និងគ្រូសីលធម៌ពលរដ្ឋវិជ្ជា ។

៣- ជំរុញលើកកម្ពស់ជំនាញបង្រៀន និងចំណេះដឹងមូលដ្ឋាននៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ។

៤- អនុវត្តវិធីសាស្ត្របង្រៀនតាមបែបទំនើបនិងមានលក្ខណៈវិទ្យាសាស្ត្រ ។

៥- គោរពតាមពិធីការនិងនីតិវិធីរបស់ក្រសួង ។

៦- ផ្ទេរជំនាញក្នុងការអប់រំនិងប្រវត្តិសាស្ត្រ ដល់មន្ត្រីរបស់ក្រសួងអប់រំ ។

៧- ធានាឲ្យបាននូវប្រសិទ្ធភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ។

## ៤) ការកំណត់ទិសដៅ

គ្រូបង្គោលថ្នាក់ជាតិនិងអ្នកជំនាញអន្តរជាតិទាំងអស់ បានធ្វើដំណើរមកបណ្ណាល័យព្រឹទ្ធសភានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ដើម្បីចូលរួមក្នុងពិធីបើកជាផ្លូវការនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ។ សិក្ខាកាមទាំងអស់បានទទួលការថ្លែងសុន្ទរកថាស្វាគមន៍ពីលោក ឌី ខាំបូលី និងលោក ឆាំង យុ ដែលបានពន្យល់អំពីគោលបំណង និងសម្ភារៈបច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តាលលើកនេះ និងវគ្គបណ្តុះបណ្តាលលើកក្រោយៗទៀត ។ លោក ខៀវ សុផល ដែលជាសិក្ខាកាមថ្នាក់ជាតិមួយរូបបានមានប្រសាសន៍ថា "ខ្ញុំបានរង់ចាំវគ្គបណ្តុះបណ្តាលរបៀបនេះអស់រយៈពេល៣០ឆ្នាំមកហើយ" ។ វគ្គបណ្តុះបណ្តាលនេះ ក៏ជាពេលវេលាមួយដែលផ្តល់ឱកាសឲ្យអ្នកជំនាញអន្តរជាតិ និងគ្រូបង្គោលថ្នាក់ជាតិសំណេះសំណាលគ្នា និងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

បន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់នៅសណ្ឋាគារជូលីណារួចមក គ្រូបង្គោលថ្នាក់ជាតិនិងអ្នកជំនាញអន្តរជាតិទាំងអស់បានធ្វើដំណើរទៅចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា នៅទីស្តីការក្រសួង ដើម្បីសំដែងការគួរសម និងទទួលអនុសាសន៍ណែនាំក៏ដូចជាកិច្ចបើកវគ្គបណ្តុះបណ្តាលជាផ្លូវការផងដែរ ។ ឯកឧត្តមបានមានប្រសាសន៍ថា ឯកឧត្តមមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើគម្រោងនេះ ហើយរូបឯកឧត្តមផ្ទាល់បានខិតខំដើម្បីបង្កើតឲ្យមានការអប់រំពី

អំពើប្រល័យពូជសាសន៍នេះអស់រយៈពេល១៥ឆ្នាំមកហើយ ។ នៅក្នុងកិច្ចដំណើរការនេះ ឯកឧត្តមបានជួបពិភាក្សាជាមួយរដ្ឋាភិបាលអូស្ត្រាលី និងក្រសួងការបរទេសសហរដ្ឋអាមេរិក ។ ឯកឧត្តមបានថ្លែងអំពីការតស៊ូ ទាំងក្នុងការកសាងសង្គមនិងការស្តារប្រព័ន្ធអប់រំឡើងវិញ ដោយសារថាខ្មែរក្រហមបានសម្លាប់គ្រូបង្រៀនប្រមាណជិត៨០ភាគរយ ។ ទោះជាមានការលំបាកនៅក្នុងអតីតកាលក្តី ឯកឧត្តម អ៊ឹម សិទ្ធី ជឿជាក់ថា បរិយាកាសនយោបាយនិងសង្គមនាពេលបច្ចុប្បន្ន មានអំណោយផលដល់ការបញ្ចូលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅក្នុងកម្មវិធីសិក្សារបស់ក្រសួង ។ ឯកឧត្តមបានប្រាប់សិក្ខាកាមទាំងអស់ថា សង្គមកម្ពុជា «បានលេងល្បែងដ៏គ្រោះថ្នាក់មួយនៅក្នុងការព្រងើយកន្តើយ ឬការបដិសេធចំពោះអំពើប្រល័យពូជសាសន៍ ។ វាមិនត្រឹមតែគ្រោះថ្នាក់សម្រាប់កម្ពុជាប៉ុណ្ណោះទេ ថែមទាំងគ្រោះថ្នាក់ចំពោះពិភពលោកទាំងមូលទៀតផង» ។ ឯកឧត្តមបានបន្ថែមថា «ក្មេងជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម ជាពិសេសអ្នកដែលរស់នៅតាមទីក្រុង គឺមានអ្វីគ្រប់បែបយ៉ាង មានអាហារ និងថវិកាសម្រាប់ចាយវាយគ្រប់គ្រាន់ ។ ប៉ុន្តែ ក្មេងទាំងនោះត្រូវតែយល់ថា មានពេលមួយនោះ យើងអត់មានអ្វីទាំងអស់» ។ ឯកឧត្តមបានបញ្ចប់ការសំណេះសំណាលដោយ បានជំរុញលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ ឲ្យខិតខំរៀនសូត្រពីសិក្ខាសាលានេះឲ្យបានហ្មត់ចត់ និងបានអរគុណសិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលាចូលរួមក្នុងគម្រោងដ៏មានសារៈសំខាន់នេះ ។

## ៥) សកម្មភាពនៅក្នុងពេលបណ្តុះបណ្តាល

នៅរៀងរាល់ថ្ងៃ សិក្ខាកាមទាំងអស់បានមកជួបជុំគ្នានៅបណ្ណាល័យព្រឹទ្ធសភា ដើម្បីពិនិត្យមើលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ទទួលការបណ្តុះបណ្តាលលើផ្នែកគរុកោសល្យ និងស្តាប់អ្នកជំនាញជាតិ និងអន្តរជាតិ ដែលធ្វើបទបង្ហាញទៅលើប្រធានបទផ្សេងៗគ្នា ។ គ្រូបង្គោលថ្នាក់ជាតិ ក៏បានបំបែកទៅជាក្រុមតូចៗមួយដងក្នុងមួយថ្ងៃ ដើម្បីអនុវត្តមេរៀន ។ ភាពយន្ត ចម្រៀង និងការសម្តែង ក៏ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលនេះដែរ ។

### ក. មេរៀនប្រវត្តិសាស្ត្រ ៈ លោក ឌី ខាំបូលី និងសាស្ត្រាចារ្យ ដេវីដ ឆេនល័រ

រៀងរាល់ព្រឹកនៃម៉ោងសិក្សា លោក ឌី ខាំបូលី និងសាស្ត្រាចារ្យ ដេវីត ឆេនល័រ បានធ្វើបទបង្ហាញនៅក្នុងសៀវភៅ«*ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ*» ចំនួនពីរជំពូក ដោយប្រើប្រាស់ power point slides ។ លោក ឌី ខាំបូលី បាននិយាយសរុបសេចក្តីសំខាន់ៗនៅក្នុងសៀវភៅរបស់លោក សម្រាប់ការពិភាក្សានិងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ។ សិក្ខាកាមបានត្រៀមខ្លួនក្នុង

ការសួរសំណួរអំពីព្រឹត្តិការណ៍ពិត ដែលបានចំណាយពេលយ៉ាងច្រើន ជាងពេលវេលាដែលបានបែងចែកសម្រាប់ផ្នែកប្រវត្តិសាស្ត្រនេះ ។

សំណួរមួយចំនួនពីសិក្ខាកាមរួមមាន ៖

១. ហេតុអ្វីបានជាតំបន់នៅក្នុងរបបខ្មែរក្រហម ត្រូវបានដាក់សម្គាល់ដោយលេខកូដ? ហេតុអ្វីបានជាតំបន់ខ្លះមានលេខកូដ ហើយតំបន់ខ្លះទៀតអត់មាន?

២. តើមេដឹកនាំខ្មែរក្រហមទទួលយកមនោគមន៍វិជ្ជាមកពីណា? តើមេដឹកនាំខ្មែរក្រហមយកគំរូនយោបាយតាមប្រទេសណាមួយឬមេដឹកនាំណាមួយដែរឬទេ?

៣. តើអ្វីទៅជាគោលដៅនយោបាយរបស់ខ្មែរក្រហម?

៤. តើរូបិយវត្ថុប្រភេទណាដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម?

៥. តើ ប៉ុល ពត ពិតជាអ្នកកាន់ព្រះពុទ្ធសាសនាដែរឬទេ?

## ខ. ការសិក្សានៅក្នុងក្រុមតូច

រយៈពេលពី២ទៅ៣ម៉ោងក្នុងមួយថ្ងៃ សិក្ខាកាមបានបំបែកទៅជាក្រុមតូចៗ ដែលក្នុងមួយក្រុមមានសមាជិក១០រូប ។ ក្រុមតូចៗនេះដឹកនាំដោយអ្នកសម្របសម្រួលអន្តរជាតិ ។ ការបំបែកទៅជាក្រុមតូចៗនេះ បានផ្តល់ឱកាសឲ្យសិក្ខាកាមទាំងអស់បេះអនុវត្តសៀវភៅណែនាំសម្រាប់គ្រូបង្រៀនជាមួយនឹងសៀវភៅប្រវត្តិសាស្ត្រ ហើយនឹងជួយដល់សិក្ខាកាមទាំងអស់ក្នុងការស្វែងយល់កាន់តែច្បាស់ថែមទៀតពីសម្ភារៈឧបទ្ទេសទាំងនេះ ។ នៅក្នុងក្រុមតូចៗនេះ សិក្ខាកាមនីមួយៗបានអនុវត្តមេរៀនគំរូនៅក្នុងសៀវភៅណែនាំ ដែលមានរយៈពេលពី៣០ទៅ៤៥នាទី ហើយសិក្ខាកាមដទៃទៀតដើរតួធ្វើជាសិស្ស ។ បន្ទាប់ពីការអនុវត្តមេរៀនរួចមក គ្រូម្នាក់ៗនឹងទទួលបានយោបល់កែលម្អពីអ្នកសម្របសម្រួលអន្តរជាតិ ។ នៅក្នុងកំឡុងពេលនេះ អ្នកសម្របសម្រួលលើកទឹកចិត្តដល់សិក្ខាកាមឲ្យប្រើប្រាស់សំណួរពិភាក្សាជាមួយនឹងសំណួរជាក់ស្តែង ហើយប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗគ្នា ។

មេរៀនគំរូខ្លះរួមមាន ៖

១. អ្នកគ្រូ មុំ ម៉េត បានចាប់ផ្តើមមេរៀនរបស់គាត់ ដោយនិយាយសួស្តី ហើយនឹងកត់អវត្តមាននៅក្នុងថ្នាក់រៀន ។ បន្ទាប់មក អ្នកគ្រូបានពិនិត្យមើលអ្វីដែលសិស្សបានសិក្សារួចហើយនៅម៉ោងមុន ដោយសួរសិស្សម្នាក់ឲ្យសង្ខេបមេរៀនចាស់ឡើងវិញ ។ បន្ទាប់ពីសិស្សសង្ខេបមេរៀនចាស់ហើយ អ្នកគ្រូបានបន្ថែមព័ត៌មានទៅលើការសង្ខេបរបស់សិស្ស ។ បន្ទាប់មក អ្នកគ្រូពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ ។ អ្នកគ្រូបានបែងចែកសិស្សជាក្រុមដែលក្នុងមួយក្រុមមានគ្នា៣នាក់ ហើយអ្នកគ្រូចាត់ឲ្យក្រុមនីមួយៗអានកថាខណ្ឌអំពីការបែងចែក

តំបន់ផ្សេងៗគ្នានៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ អ្នកគ្រូណែនាំសិស្សនៅក្នុងក្រុមនីមួយៗឲ្យកត់ត្រានូវព្រឹត្តិការណ៍ជាក់ស្តែងសំខាន់ៗនៅក្នុងកថាខណ្ឌរៀងៗខ្លួន ។ បន្ទាប់មក ក្រុមនីមួយៗឡើងបង្ហាញអំពីអ្វីដែលខ្លួនបានកត់ត្រា ទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ។ នៅចុងបញ្ចប់ អ្នកគ្រូបានសួរសំណួរបើកទៅសិស្ស ដោយឲ្យសិស្សឆ្លើយទៅនឹងសំណួរដូចជា «ប្រៀបធៀបភាពខុសគ្នារវាងភូមិភាគនីមួយៗ ហើយពន្យល់ថាហេតុអ្វីបានជាភូមិភាគនីមួយៗមានទំហំខុសគ្នា?» អ្នកគ្រូបានឲ្យសិស្សបង្ហាញពីសមតិកម្មរបស់ខ្លួនទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ។ អ្នកគ្រូបានបញ្ចប់មេរៀន ដោយធ្វើការសង្ខេបអ្វីដែលសិស្សបានរៀននៅថ្ងៃនេះ និងដាក់កិច្ចការឲ្យសិស្សធ្វើនៅផ្ទះ ។

២. លោកគ្រូ ស៊ីវ ធួន ចាប់ផ្តើមមេរៀនដោយនិយាយសួស្តី និងសួរអវត្តមាននៅក្នុងថ្នាក់ ។ បន្ទាប់មក លោកគ្រូពិនិត្យមើលទៅលើអ្វី ដែលសិស្សបានរៀនកាលពីម៉ោងមុន ដោយឲ្យសិស្សម្នាក់សង្ខេបមេរៀនចាស់ឡើងវិញ ។ លោកគ្រូបានបង្ហាញរូបថតនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយឲ្យសិស្សពន្យល់ ថាតើរូបថតនេះបង្ហាញអំពីអ្វី ។ លោកគ្រូសួរសំណួរទៅកាន់សិស្សទាំងអស់ថា «ហេតុអ្វីបានជាប្អូនគិតថា ប្រជាជនបានលាក់ខ្លួននៅក្នុងផ្ទះ?» បន្ទាប់មក លោកគ្រូបានបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ហើយបានចាត់តាំងសិស្សពីរនាក់ក្នុងក្រុមនីមួយៗ ដែលម្នាក់ជាអ្នកដឹកនាំក្រុម និងម្នាក់ទៀតជាលេខា ។ លោកគ្រូបានប្រាប់ទៅសិស្សថា វាគ្មិនមួយរូបនឹងមកធ្វើបទបង្ហាញ ហើយសិស្សក្នុងក្រុមនីមួយៗត្រូវសរសេររបាយការណ៍អំពីអ្វីដែលខ្លួនបានរៀន ។ បន្ទាប់មក វាគ្មិនបានឡើងមករៀបរាប់អំពីជីវិតរបស់គាត់ដែលជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ បន្ទាប់ពីវាគ្មិនបានផ្តល់បទបង្ហាញរួចមក លោកគ្រូបានឲ្យក្រុមនីមួយៗរាយការណ៍អំពីអ្វីដែលវាគ្មិនបាននិយាយ ។

អ្នកសម្របសម្រួលក្នុងក្រុមតូចៗ ត្រូវបានស្នើឲ្យឡើងបង្ហាញមេរៀនគំរូ សម្រាប់ក្រុមរបស់ខ្លួន ។ ខាងក្រោមនេះគឺជាមេរៀនគំរូ ដែលបង្ហាញដោយ សារ៉ា ចនឌិកគិន ។

១. សារ៉ា ធ្វើគំរូមេរៀនដោយផ្អែកលើមេរៀនបទសម្ភាសន៍ ដែលដកស្រង់ចេញពីជំពូកទី៧ នៃសៀវភៅណែនាំគ្រូ ។ សារ៉ា ចាប់ផ្តើមមេរៀនដោយសួរវត្តមានសិស្សនៅក្នុងថ្នាក់ និងឲ្យសិស្សម្នាក់ពន្យល់មេរៀនពីថ្ងៃមុន ។ បន្ទាប់មក គាត់ប្រាប់សិស្សអំពីអ្វីដែលសិស្សត្រូវរៀននៅថ្ងៃនេះ ដែលរួមមានការយល់ដឹងអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ នៅក្នុងការធ្វើសម្ភាសន៍ និងចំណុចអវិជ្ជមានមួយចំនួន ដែលអាចកើតមានឡើង ដែលជាលទ្ធផលនៃការធ្វើសម្ភាសន៍ ។

គាត់ប្រាប់សិស្សថា នៅសប្តាហ៍ក្រោយ សិស្សនឹងត្រូវទៅសម្ភាសមនុស្សម្នាក់ដែលទទួលរងផលប៉ះពាល់ពីរបបខ្មែរក្រហម ។ ប៉ុន្តែ សិស្សទាំងអស់ត្រូវតែសិក្សាអំពីបច្ចេកទេស និងវិធីសាស្រ្តសម្ភាសន៍ពេញមួយសប្តាហ៍ ដើម្បីរៀបចំខ្លួនសម្រាប់ការសម្ភាសន៍ ។ គាត់បានបែងចែកក្តារខៀនជាពីរផ្នែក ហើយឲ្យសិស្សផ្តល់ចំណុចល្អនិងចំណុចអាក្រក់ ដែលអាចកើតមានឡើងក្នុងអំឡុងពេលនៃបទសម្ភាសន៍ ។ ដើម្បីកែលម្អនិងបន្ថែមទៅលើចម្លើយរបស់សិស្ស គាត់បានធ្វើសេចក្តីសង្ខេប ទៅលើអ្វីដែលសិស្សបាននិយាយ និងសរសេរសេចក្តីសង្ខេបនោះនៅលើក្តារខៀន ។ បន្ទាប់មក អ្នកសម្របសម្រួលបានឲ្យសិស្សចាប់ដៃគូ ហើយបង្កើតសំណួរសំខាន់៥ ដែលសិស្សត្រូវសួរទៅជនរងគ្រោះនៃរបបខ្មែរក្រហម និងសំណួរពីរទៀតដែលសិស្សគួរចៀសវាង ។ ក្រុមនីមួយៗឡើងបង្ហាញសំណួររបស់ខ្លួនទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ហើយអ្នកសម្របសម្រួលសរសេរសំណួរដាក់លើក្តារខៀន ។ អ្នកសម្របសម្រួលសង្ខេបអំពីអ្វីដែលសិស្សបានរៀននៅថ្ងៃនេះ ហើយដាក់កិច្ចការឲ្យសិស្សធ្វើនៅផ្ទះ ដោយឲ្យសិស្សសរសេរកថាខណ្ឌពី៤ទៅ៥ អំពីសារៈសំខាន់នៃបទសម្ភាសន៍ ។ បន្ទាប់ពីបញ្ចប់ការឡើងធ្វើមេរៀនគំរូ គាត់បានពន្យល់អំពីមូលហេតុនៃការអនុវត្តន៍មេរៀនតាមវិធីសាស្រ្តបៀបនេះ ដោយគាត់ចង់សង្កត់ធ្ងន់ទៅលើមេរៀនមួយដែលមិនមានចម្លើយ“ខុស”ឬ“ត្រូវ” ។ វិធីសាស្រ្តបង្រៀនរបៀបនេះ លើកទឹកចិត្តដល់សិស្សឲ្យចេះពិចារណាដោយខ្លួនឯង ។

ខាងក្រោមនេះគឺជាមេរៀនគំរូ ដែលអនុវត្តដោយលោក គ្រីស ឌៀរីង ៖

២. គ្រីស បានសម្រេចចិត្តបង្រៀនមេរៀនគំរូ ទៅលើមេរៀនពន្យល់ពាក្យនៅក្នុងជំពូកទី៣ ។ គាត់បានពន្យល់ដល់សិក្ខាកាមទាំងអស់ថា គាត់នឹងបង្រៀនជាគំរូផងនិងពន្យល់ថាតើគាត់កំពុងធ្វើអ្វីនៅក្នុងកំឡុងពេលនៃការបង្រៀន ។ ពេលគាត់ឡើងបង្រៀន សិក្ខាកាមត្រូវតែដើរតួជាកូនសិស្ស ។ នៅពេលគាត់ឲ្យសញ្ញាមកថា “គាត់ចាកចេញពីការបង្រៀនគំរូ” គាត់នឹងពន្យល់ពីមូលហេតុនៅក្នុងចំណុចនីមួយៗនៃមេរៀនរបស់គាត់ ។ សិក្ខាកាមក៏មានឱកាសក្នុងការចោទសួរទៅលើចំណុចទាំងឡាយ ដែលខ្លួនមានការយល់ច្រឡំក្នុងកំឡុងពេលដែលគាត់ចាកចេញពីការបង្រៀនគំរូ ។ គ្រីស ចាប់ផ្តើមមេរៀនដោយសរសេរពាក្យ“ប្រព័ន្ធសេដ្ឋកិច្ច” នៅខាងលើនៃក្តារខៀន ហើយបានគូរប្រអប់តូចមួយដែលបង្ហាញអំពីប្រភេទនៃព័ត៌មាន ។ គាត់បានសួរសិក្ខាកាមថា “តើអ្វីទៅគឺជាប្រព័ន្ធសេដ្ឋកិច្ច នៅក្នុងពន្យល់ពាក្យនៃជំពូកទី២?” សិក្ខាកាមបានផ្តល់ចម្លើយ ហើយអ្នកសម្របសម្រួលបានសរសេរចម្លើយនៅលើក្តារខៀន ដោយឲ្យយោបល់បន្ថែមដើម្បីលើកទឹកចិត្តដល់សិស្ស ។ បន្ទាប់មក គាត់បានសួរសិស្សថា “តើមាន

*ប្រព័ន្ធសេដ្ឋកិច្ចផ្សេងទៀតដែលអ្នកបានដឹង ហើយមិនមាននៅក្នុងបញ្ជីនេះដែរឬទេ?» សិក្ខាកាមបានឆ្លើយតបថា «ប្រព័ន្ធសេដ្ឋកិច្ចបែបសង្គមនិយម និងប្រព័ន្ធសេដ្ឋកិច្ចបែបមូលធននិយម» ។ បន្ទាប់មក គាត់បានផ្តល់ការកែលម្អជាវិជ្ជមាន ដោយឲ្យយោបល់ទៅលើចម្លើយរបស់សិក្ខាកាម ។ គាត់បានផ្តល់យោបល់សង្ខេប ហើយបានសួរសិក្ខាកាមថា តើ«កសិករ»គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែរឬទេ? ។ សិក្ខាកាមបានឆ្លើយថា«មិនមែនទេ» ។ គាត់បានឲ្យសិស្សផ្តល់យោបល់មកគាត់វិញថា តើពាក្យ«កសិករ» គួរតែដាក់នៅក្នុងប្រភេទប្រព័ន្ធសេដ្ឋកិច្ចណាមួយ?*

*បន្ទាប់មក គាត់បានបែកចែកសិស្សជាពីរក្រុម ហើយបានឲ្យសិស្សមួយក្រុមសរសេរអំពីជីវិតរស់នៅក្រោមរបបមូលធននិយម និងសិស្សមួយក្រុមទៀតសរសេរអំពីជីវិតរស់នៅក្រោមរបបកុម្មុយនីស្តនិយម ។ គាត់បានឲ្យសិស្សនៅក្នុងក្រុមនីមួយៗ ធ្វើហាក់ដូចជាខ្លួនកំពុងរស់នៅក្រោមប្រព័ន្ធសេដ្ឋកិច្ចដែលគ្រូកំណត់ឲ្យសិក្សា ហើយពណ៌នាថា តើជីវិតរបស់ខ្លួននឹងទៅជាយ៉ាងណា ប្រសិនបើខ្លួនរស់នៅក្នុងប្រព័ន្ធនោះ ។ បន្ទាប់មកទៀត គាត់បានជ្រើសរើសសិស្សមួយចំនួនចេញពីក្រុមនីមួយៗ (ក្រុមដែលសិក្សាពីរបបមូលធននិយម និងក្រុមដែលសិក្សាពីរបបកុម្មុយនីស្ត) ឲ្យអានសាច់រឿង ឬការពណ៌នាពីជីវិតនៅក្រោមប្រព័ន្ធសេដ្ឋកិច្ចរៀងៗខ្លួន ។ បន្ទាប់មក អ្នកសម្របសម្រួលបានលើកជាសំណួរថា ៖ តើអ្វីទៅជាភាពខុសគ្នារវាង «មូលធននិយម»និង«កុម្មុយនីស្តនិយម»?*

*អ្នកសម្របសម្រួលបញ្ចប់មេរៀន ដោយសួរសំណួរទៅសិក្ខាកាមថា «តើយើងបានរៀនអ្វីខ្លះ?» ដើម្បីវាយតម្លៃការយល់ដឹងរបស់សិក្ខាកាម និងដើម្បីធ្វើជាគំរូឲ្យសិក្ខាកាមអាចសង្ខេបមេរៀននៅក្នុងថ្នាក់រៀនរបស់ខ្លួនបាន ។*

### គ. អ្នកជំនាញជាតិ អន្តរជាតិ និងវាគ្មិន

**រស់ ចន្ទ្រាបុត្រ** ៖ *លោកគឺជាអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ។ លោកបានធ្វើបទបង្ហាញអំពីប្រវត្តិនៃដំណើរការផ្លាស់ប្តូរនយោបាយពីរាជានិយមទៅសាធារណរដ្ឋខ្មែរ ។ លោកបានសង្កត់ធ្ងន់ទៅលើជម្លោះរវាងរាជវង្សានុវង្សខ្មែរ (ខ្សែនរោត្តមនិងខ្សែស៊ីសុវត្ថិ) ថាជាស្នូលនៃភាពរីកររាលដាលនយោបាយក្នុងទសវត្សរ៍ឆ្នាំ១៩៥០និង១៩៦០ ។ នៅក្នុងបទបង្ហាញរបស់លោកនៅថ្ងៃទី២៩ ខែមិថុនា លោកសាស្ត្រាចារ្យសង្កត់ធ្ងន់ទៅលើការខ្វល់ខ្វាយរបស់សម្តេចព្រះ នរោត្តម សីហនុ ចំពោះប្រទេសមហាអំណាច និងឥទ្ធិពលរបស់កុម្មុយនីស្តមកលើប្រទេសកម្ពុជា ។ ដោយសារឥស្សរជនកម្ពុជាមួយចំនួនមានទំនាក់ទំនងឬទទួលឥទ្ធិពលពីកុម្មុយនីស្ត សម្តេចព្រះ នរោត្តម សីហនុ បានដាក់សម្ពាធទៅលើមន្ត្រីរបស់*

ព្រះអង្គដែលមានចេតនាចូលរួម ឬគាំទ្រប្រទេសមហាអំណាចកុម្មុយនីស្ត ក៏ដូចជាប្រទេសមហាអំណាចផ្សេងៗទៀត ដូចជាសហរដ្ឋអាមេរិកជាដើម ។

នៅទសវត្សរ៍ឆ្នាំ១៩៥០ មន្ត្រីរបស់ព្រះអង្គមួយចំនួន បានធ្វើទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ហើយមានបំណងធ្វើរដ្ឋប្រហារ ។ បញ្ហានេះបានធ្វើឲ្យព្រះអង្គមានការព្រួយបារម្ភយ៉ាងខ្លាំង ហើយព្រះអង្គបានព្យាយាមអស់ពីសមត្ថភាព ក្នុងការទប់ស្កាត់មន្ត្រីរបស់ព្រះអង្គកុំឲ្យចូលរួមជាមួយភ្នាក់ងារអាមេរិកាំង ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ គ្រូបង្រៀននិងឥស្សរជនខ្មែរមួយចំនួនបានបាត់ខ្លួន ។ ទោះបីជាការបាត់ខ្លួនរបស់អ្នកទាំងនេះ មិនទាន់បានដឹងមូលហេតុច្បាស់លាស់យ៉ាងណាក៏ដោយ ក៏សម្តេចព្រះ នរោត្តម សីហនុ បានចាត់ទុកថា អ្នកបាត់ខ្លួនទាំងនោះគឺជាអ្នកឆ្វេងនិយម និងជាជនកុម្មុយនីស្ត ។ រដ្ឋាភិបាលបានដាក់សម្ពាធទៅលើគ្រូបង្រៀន ។ រដ្ឋាភិបាលមានការព្រួយបារម្ភថា គ្រូនឹងបង្រៀនអំពីនយោបាយ ។ ពេលដែលក្រុមកុម្មុយនីស្តបានពង្រីកអំណាចយ៉ាងលឿន ហើយអ្នកឆ្វេងនិយមខ្មែរបាត់ខ្លួនកាន់តែច្រើនឡើងៗ សម្តេចព្រះ នរោត្តម សីហនុ បានចាប់ផ្តើមដាក់សម្ពាធទៅលើគ្រូបង្រៀន ។ គ្រូបង្រៀនមិនត្រូវបានអនុញ្ញាតឲ្យពិភាក្សាជាសាធារណៈ ចាប់ពី៤ឬ៥នាក់ឡើងទៅ ។

នៅឆ្នាំ១៩៦៧ ប្រជាជននៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ខឹងសម្បានឹងនយោបាយពុករលួយរបស់រាជរដ្ឋាភិបាល ។ ទាហានរដ្ឋាភិបាលបានដណ្តើមយកដីធ្លីរបស់ប្រជាជន ។ នៅពេលប្រជាជនធ្វើការតវ៉ា រដ្ឋាភិបាលបានឆ្លើយតបដោយការកាប់សម្លាប់យ៉ាងសាហាវយង់ឃ្នង ដូចជាដុតផ្ទះសម្បែង និងកាត់ក្បាលអ្នកដឹកនាំធ្វើបាតុកម្មជាដើម ។

**អាឡិច ហ៊ីនតុន** : លោកគឺជាសាស្ត្រាចារ្យផ្នែកនរវិទ្យា នៅសកលវិទ្យាល័យរ៉ាត់ហ្គ័រ សហរដ្ឋអាមេរិក ។ លោកបានធ្វើបទបង្ហាញនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ លើប្រធានបទ (ការពិតការបង្ហាញ និងនយោបាយនៃការចងចាំ បន្ទាប់ពីអំពើប្រល័យពូជសាសន៍) ។ លោកបានពិពណ៌នាអំពីការអប់រំពីរប្រភេទ : ការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ ។ លោកបានពន្យល់ថាការអប់រំទាំងពីរប្រភេទនេះអាចកើតឡើងនៅទីតាំងនៃការចងចាំ ។ បន្ទាប់មក លោកបានពិនិត្យមើលរយៈកាលនៃការចងចាំផ្សេងៗគ្នា ដែលសង្គមកម្ពុជាបានជួបប្រទះតាំងពីជំនាន់ ប៉ុល ពត :

ក. **របបខ្មែរក្រហម** : លោកសាស្ត្រាចារ្យបានអះអាងថា ជំនាន់ ប៉ុល ពត គឺជាពេលវេលាមួយ ពេលដែលការចងចាំគឺជាឧក្រិដ្ឋកម្ម ហើយខ្មែរក្រហមប៉ុនប៉ងលុបបំបាត់ការចងចាំនោះចោល ។ ប្រជាជនបានចាកចេញពីទីតាំងនៃការចងចាំ គឺជាទីកន្លែងដែលប្រជាជនធ្លាប់រស់នៅ និងផ្លូវដែលគាត់ធ្លាប់ដើរ ។ លោកក៏បានមានប្រសាសន៍ផងដែរថា ប៉ុល ពត ព្យាយាមបំផ្លាញការចងចាំអំពីព្រះពុទ្ធសាសនា ការអប់រំ និងទំនាក់ទំនងពាណិជ្ជកម្ម ដោយបំផ្លាញចោលនូវក្របខ័ណ្ឌ

ការងាររបស់ស្ថាប័នទាំងនោះ ។ នៅក្នុងរយៈកាលនោះ ប្រសិនបើប្រជាជនគិតអំពីអតីតកាល ពួកគាត់នឹងត្រូវបានចោទប្រកាន់ថា មានជំងឺសតិអារម្មណ៍ ហើយអាចត្រូវបានសម្លាប់ចោល ។ និយាយជារួម វិធីដែលមានប្រសិទ្ធភាពបំផុតដើម្បីលុបបំបាត់ការចងចាំ គឺការកម្ទេចប្រជាជន ។

**ខ. របបសាធារណរដ្ឋប្រជាមានិតកម្ពុជា** : លោកសាស្ត្រាចារ្យបានអះអាងថា នយោបាយនៃការចងចាំបានលេចជារូបរាងឡើងនៅក្នុងសង្គម ក៏ដូចជានៅក្នុងប្រព័ន្ធអប់រំ ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចាប់ផ្ដើមរៀបរាប់ពីអតីតកាលដែលទើបតែកន្លងផុតថ្មីៗ ដែលគាំទ្រដល់ភាពស្របច្បាប់របស់ខ្លួនទាំងនៅក្នុងនិងក្រៅប្រទេស ។ សៀវភៅរៀនអាននៅតាមសាលាបឋមសិក្សា បានបញ្ចូលរូបភាពនិងរឿងរ៉ាវនៃអំពើហិង្សានៅក្នុងរបបខ្មែរក្រហម ជាផ្នែកមួយនៃការឃោសនារបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

**គ. រយៈកាលនៃសម័យអ៊ុនតាក់** : រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ត្រូវបានដកចេញពីកម្មវិធីសិក្សា ។ មិនមានការបញ្ជាក់ច្បាស់លាស់អំពីហេតុផលក្នុងការបំភ្លេចរឿងរ៉ាវនេះចោល ទោះបីជារដ្ឋាភិបាលបានអនុញ្ញាតឲ្យមានការឈប់សម្រាក ដើម្បីរំលឹកដល់រយៈកាលនោះក៏ដោយ ។

**ឃ. សម័យបច្ចុប្បន្ន** : លោកសាស្ត្រាចារ្យបានអះអាងថា ប្រទេសកម្ពុជាស្ថិតនៅក្នុងការចងចាំអន្តរកាល ដោយលោកបានសង្កត់ធ្ងន់ថា តុលាការនិងគម្រោងស្ដីពីការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យនាពេលបច្ចុប្បន្ន គឺជាការធ្វើឡើងវិញនូវកិច្ចខិតខំប្រឹងប្រែងក្នុងអតីតកាល ។

លោកសាស្ត្រាចារ្យបានបញ្ចប់បទបង្ហាញរបស់លោក ដោយបានលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ថា «អ្នកទាំងអស់គ្នាកំពុងតែបង្កើតប្រវត្តិសាស្ត្រ ដូចដែលតុលាការកំពុងបង្កើតប្រវត្តិសាស្ត្រដូច្នោះដែរ» ។ លោកបានលើកទឹកចិត្តគ្រូបង្គោលថ្នាក់ជាតិទាំងអស់ ឲ្យត្រិះរិះពិចារណាអំពីរឿងរ៉ាវក្នុងអតីតកាលនិងសួរសំណួរពិបាកៗ ។ ជាសេចក្ដីសន្និដ្ឋាន លោកនិយាយថា «ទោះបីជាយើងផ្ដន្ទាទោសឧក្រិដ្ឋកម្មនេះ និងទាមទារឲ្យមានការទទួលខុសត្រូវយ៉ាងណាក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់ថា ពិភពលោកមិនមែនត្រូវបានបែងចែកជាខ្មៅនិងសជានិច្ចកាលនោះទេ ហើយយើងត្រូវតែទទួលស្គាល់ថា ពិភពលោកនេះគឺពោរពេញទៅដោយមនុស្សជាតិ» ។

**ចន ឆរឈីអារី** : លោកគឺជាសាស្ត្រាចារ្យ បង្រៀននៅមហាវិទ្យាល័យមីឈីហ្កែន សហរដ្ឋអាមេរិក ។ លោកបានធ្វើបទបង្ហាញនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ស្ដីអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬត្រូវបានស្គាល់ជាទូទៅថា សាលាក្ដីខ្មែរក្រហម ។ លោកបានពន្យល់អំពីកិច្ចការដែលអង្គជំនុំជម្រះ

បានដាក់ចេញដើម្បីសម្រេចឲ្យបាន ដែលរួមមានការអនុវត្តការកាត់សេចក្តីផ្នែកព្រហ្មទណ្ឌ និងការនាំយកយុត្តិធម៌មកជូនជនរងគ្រោះ ។ លោកក៏បានពន្យល់ផងដែរថា អង្គជំនុំជម្រះមានតួនាទីក្នុងការ“ប្រាប់ការពិត” ឬនិយាយម្យ៉ាងទៀតថា អង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការបង្កើតឡើងនូវការពិតឥតលម្អៀងនៅក្នុងរបបខ្មែរក្រហម ដោយព្យាយាមរកឲ្យឃើញថា មានអ្វីកើតឡើងពិតប្រាកដ ។ អង្គជំនុំជម្រះក៏មានការទទួលខុសត្រូវចំពោះមុខសហគមន៍អន្តរជាតិដែរ ៖ អង្គជំនុំជម្រះនេះគឺជាតុលាការ“កូនកាត់”ដំបូងបង្អស់ ឬហៅម្យ៉ាងទៀតថាតុលាការចម្រុះអន្តរជាតិ ។ លោកបានថ្លែងដោយសង្ខេបអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ និងទម្រង់ផ្លូវច្បាប់របស់តុលាការនេះ ដូចជាការចូលរួមរបស់ជនរងគ្រោះ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីជាដើម ។

**៤៤ ដឺហ្គាស ៖** លោកគឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យម៉ាស្សាជូសេត និងជាសាស្ត្រាចារ្យផ្នែកការសិក្សាពីអាស៊ីនៅសាកលវិទ្យាល័យខកនែល សហរដ្ឋអាមេរិក ។ លោកបាននិយាយអំពីរបួសផ្លូវចិត្ត និងទំនាក់ទំនងជាមួយជនភៀសខ្លួនខ្មែរ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ។ ដំបូង លោកនិយាយអំពីសេចក្តីផ្តើមនៃជំងឺផ្លូវចិត្ត និងឥទ្ធិពលនៃជំងឺផ្លូវចិត្តទៅលើចិត្តសាស្ត្រ ។ លោកបានពន្យល់ថា វាមានបញ្ហាផ្នែកភាសាក្នុងការពណ៌នាអំពីបទពិសោធន៍នៃការប៉ះពាល់ផ្លូវចិត្ត ដែលលោកបានអះអាងថា នេះគឺជាមូលហេតុមួយ ដែលអ្នកនៅរស់រានមានជីវិតជ្រើសរើសយកភាពស្ងៀមស្ងាត់ ជាជាងការនិយាយចេញមក ។ ទោះជាយ៉ាងនេះក្តី លោកបានព្រមានចំពោះគ្រោះថ្នាក់ដែលបណ្តាលមកពីការមិននិយាយស្តី ។ លោកបានដកស្រង់សម្តីរបស់លោក អេលី វីសែល ដែលជាអ្នកនៅរស់រានមានជីវិតពី ហូឡូខសដ៏ល្បីល្បាញម្នាក់ ដែលបាននិយាយថា “ប្រសិនបើយើងមិននិយាយ អ្នកដែលបានស្លាប់ទៅនឹងស្លាប់ពីរដង៖ ទីមួយ គឺស្លាប់ដោយសារជនដៃដល់សម្លាប់ ។ ទីពីរ គឺស្លាប់ដោយសារត្រូវបានបំភ្លេចចោល” ។ បន្ទាប់មក លោកបានបង្ហាញកំណាព្យ ដែលសរសេរដោយជនភៀសខ្លួនខ្មែរនៅសហរដ្ឋអាមេរិក ។ លោកចង់ឲ្យសិក្ខាកាមទាំងអស់សួរខ្លួនឯងនូវសំណួរមួយចំនួនដូចខាងក្រោម ៖

- តើអ្វីទៅជាឱកាសឬជាហានិភ័យ ដែលអ្នកនិពន្ធប្រឈមមុខក្នុងការរៀបរាប់រឿងរ៉ាវរបស់ខ្លួន?
- តើអ្នកនិពន្ធពុះពារបញ្ហាភាសាបានយ៉ាងដូចម្តេច?
- តើអ្វីទៅជាអត្តសញ្ញាណថ្មី នៅពេលដែលអ្នកនិពន្ធសរសេរអំពីរបួសផ្លូវចិត្តរបស់គាត់?
- តើអ្វីទៅជាគោលបំណងរបស់សាក្សី? តើសាក្សីនិយាយតំណាងឲ្យអ្នកណា?
- តើអ្នកនិពន្ធនិងអ្នកនៅរស់រានមានជីវិត ចង់ព្យុអំពីអ្វី?

លោកបានពន្យល់ថា នៅទីបញ្ចប់ អ្នកដែលនៅរស់រានមានជីវិតចង់ឲ្យមនុស្សម្នាក់និយាយថា«ខ្ញុំជឿអ្នក ។ ខ្ញុំជឿថាអ្វីដែលអ្នកបានប្រាប់គឺជាការពិត» ។ លោកក៏បានពន្យល់ដែរថា កំណាព្យគឺជាវិធីមួយសម្រាប់អ្នកដែលនៅរស់រានមានជីវិត ក្នុងការគ្រប់គ្រងរបួសផ្លូវចិត្តរបស់ខ្លួន និងបញ្ចូលបទពិសោធន៍របួសផ្លូវចិត្តទៅក្នុងស្មារតីនិងការចងចាំ ។

**ហ្វ្រែង ឆក :** លោកគឺជាអតីតប្រធានសារមន្ទីរនៃការចងចាំអំពីហ្វូឡូខស នៅទីក្រុងម៉ុងរេអាល់ ប្រទេសកាណាដា និងជាប្រធានវិទ្យាស្ថានសម្រាប់ការសិក្សាពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស នៅក្នុងទីក្រុងម៉ុងរេអាល់ ។ លោកក៏ជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យ កុងខដឌៀ ម្នាក់ដែរ ។ លោកបានធ្វើបទបង្ហាញអំពីប្រធានបទទាក់ទងទៅនឹង «អំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសាកលលោក» នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ។ ដំបូង លោកពិនិត្យមើលទៅលើនិយមន័យជាមូលដ្ឋាន និងផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍ ។ លោកបានពន្យល់ថា អំពើប្រល័យពូជសាសន៍ត្រូវបានកំណត់ថាជាការសម្លាប់ និងសកម្មភាពផ្សេងៗដែលមានចេតនាសម្លាប់ ឬធ្វើទុក្ខទោសដល់មនុស្សមួយក្រុមដោយឈរលើហេតុផល ពូជសាសន៍ សាសនា ជាតិ ឬ ជាតិពន្ធុ ។ បន្ទាប់មក លោកបានឲ្យនិយមន័យតាមផ្លូវច្បាប់នៅក្នុងមាត្រា២ នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការបង្ការនិងការផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ។ លោកបានពន្យល់ដល់គ្រូបង្គោលថ្នាក់ជាតិថា អនុសញ្ញាអង្គការសហប្រជាជាតិមិនបានរួមបញ្ចូលក្រុមអ្នកនយោបាយនិងក្រុមសង្គមទេ ហើយលោកចាត់ទុកប្រការនេះថា ជាចន្លោះប្រហោងដ៏ធំមួយ ។ លោកបានបញ្ជាក់ថា ខ្មែរក្រហមគឺជាឧទាហរណ៍មួយដ៏ល្អ ដែលយើងមិនគួរដកក្រុមសង្គមនិងក្រុមនយោបាយ ចេញពីនិយមន័យតាមផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍ឡើយ ។ លោកក៏បានលើកឡើងក្រុមពីរក្នុងរយៈកាលនៃហ្វូឡូខស ដែលមិនទទួលបានការការពារពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឡើយ ។ ក្រុមទាំងពីរនោះគឺ«ការសម្លាប់របស់អង្គការណាហ្ស៊ីទៅលើអ្នកជំងឺផ្លូវចិត្តក្នុងឆ្នាំ១៩៣៩ និងអ្នកដែលស្រឡាញ់ភេទដូចគ្នា» ។ លោកសាស្ត្រាចារ្យក៏បានចង្អុលបង្ហាញចន្លោះប្រហោងមួយទៀតនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ។ លោកបានអះអាងថា វាមានការពិបាកណាស់ក្នុងការបញ្ជាក់ថា ជនដៃដល់មានចេតនាក្នុងការកម្ទេចចោលក្រុមមួយទាំងមូល ។ ជាទូទៅនៅពេលដែលចេតនានេះត្រូវបានរកឃើញ សមាជិកក្រុមទាំងអស់ឬស្ទើរតែទាំងអស់បានស្លាប់អស់ទៅហើយ ។

បន្ទាប់មក លោកសាស្ត្រាចារ្យ ហ្វ្រែង ឆក បានលើកទឹកចិត្តដល់គ្រូបង្គោលថ្នាក់ជាតិទាំងអស់ឲ្យពិចារណាពីអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសកលលោក និងបង្ហាញអំពីទស្សនខុសៗគ្នាសម្រាប់កិច្ចតែងការបង្រៀននៅក្នុងថ្នាក់ ៖ គ្រូអាចណែនាំឲ្យសិស្សសិក្សាទៅលើអំពើប្រល័យពូជសាសន៍ផ្សេងៗ

គ្នា ហើយឆ្លើយទៅនឹងសំណួរខាងក្រោម ៖ អ្នកណាជាក្រុមជនដៃដល់ និងក្រុមជនរងគ្រោះ? តើអ្វីទៅជាការជំរុញលើកទឹកចិត្តចម្បងដល់ជនដៃដល់? តើអំពើប្រល័យពូជសាសន៍ដែលគ្រូកំណត់ឲ្យសិក្សាខុសពីរបបខ្មែរក្រហមដូចម្ដេចខ្លះ? តើវាមានភាពប្រហាក់ប្រហែលគ្នាដូចម្ដេចខ្លះ?

បន្ទាប់មក សិក្ខាកាមមានឱកាសសួរសំណួរទៅលោកសាស្ត្រចារ្យ ហ្វ្រែង ឆក ដូចជា ៖

១- ហេតុអ្វីបានជាយើងមិនបញ្ចូល ឡេនីន និង ស្តាលីន ទៅក្នុងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផង?

២- ហេតុអ្វីបានជាតែងតែមានការយឺតយ៉ាវ ក្នុងការធ្វើអន្តរាគមន៍?

៣- អំពើប្រល័យពូជសាសន៍បានកើតមានឡើងនៅក្នុងប្រទេសផ្សេងទៀត ប៉ុន្តែប្រទេសកម្ពុជាគឺជាឧទាហរណ៍តែមួយគត់ ដែលជនជាតិខ្មែរសម្លាប់ជនជាតិខ្មែរ ។ តើលោកគិតថា កម្ពុជាត្រូវការដំណោះស្រាយផ្សេងៗចំពោះការផ្សះផ្សាជាតិដែរទេ?

**ឡូរ៉ា សាំម័រ ៖** លោកស្រីគឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យហុល ចក្រភពអង់គ្លេស ។ លោកស្រីបានធ្វើបទបង្ហាញអំពីប្រវត្តិខេត្តប៉ៃលិន នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ។ លោកស្រីសម្រេចចិត្តធ្វើបទបង្ហាញទៅលើប្រធានបទនេះ ពីព្រោះលោកស្រីជឿជាក់ថា មនុស្សម្នាក់នឹងអាចធ្វើការសង្កេតអំពីរបៀបនៃការបែងចែកនៅក្នុងដួរកង់ទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ។ ហើយចេញពីនេះ មនុស្សម្នាក់នឹងអាចមើលឃើញនិងចាប់ផ្តើមដោះស្រាយ ជាមួយនឹងបញ្ហានៃភាពមិនពេញលេញរបស់រដ្ឋាភិបាលមួយ ។ ដោយប្រើប្រាស់រូបថតនៃវត្តភ្នំយ៉ាត ព្រះរាជដំណាក់របស់សម្ដេចព្រះ នរោត្តម សីហនុ និងទីប្រជុំជនក្នុងក្រុងប៉ៃលិន លោកស្រីបានបង្ហាញអំពីការប្រែក្លាយទីក្រុងប៉ៃលិន ទៅជាមជ្ឈមណ្ឌលនយោបាយ និងសេដ្ឋកិច្ច ប្រកបដោយការរៀបចំបានយ៉ាងល្អ ក្នុងកំឡុងពេល៤ឆ្នាំ មុនការបះបោរ ។

### វាគ្មិនជាតិ

**នង ចាន់ផល ៖** លោកគឺជាក្មេងម្នាក់ដែលនៅរស់រានមានជីវិតពីគុកទួលស្លែង ។ លោកបាននិយាយប្រកបដោយភាពក្ដុកក្ដួល នៅព្រឹកថ្ងៃទី១ខែកក្កដា ឆ្នាំ២០០៩ ។ លោកបានពន្យល់ថា លោកគឺជាសមាជិកក្រុមជួសជុលរថភ្លើង ដែលត្រូវបានចាប់បញ្ជូនមកទួលស្លែង ។ លោកបានមកដល់ទួលស្លែងជាមួយម្ដាយនិងបងប្អូនប្រុសស្រី៣នាក់ទៀត ។ ម្ដាយរបស់លោកត្រូវបាននាំយកទៅឃុំនៅជាន់ទីពីរនៃគុកទួលស្លែង ហើយក្មេងៗត្រូវបានយកទៅដាក់នៅជាន់ផ្ទាល់ដី ។ លោកបានពន្យល់ថា នេះគឺជាពេលចុងក្រោយបង្អស់ដែលលោកបានមើលឃើញម្ដាយរបស់លោក ។ បន្ទាប់មក លោកបានយំ ។ បន្ទាប់ពីវៀតណាមវាយចូលមកប្រទេសកម្ពុជា លោកត្រូវបាននាំយកទៅមន្ទីរពេទ្យភ្នំពេញ ។ កងទ័ពវៀតណាមម្នាក់ និងកងទ័ពកម្ពុជាម្នាក់គិតថា លោកគឺជាកូនរបស់ ប៉ុល ពត ។ លោកបានធ្វើដំណើរពីកន្លែងមួយ

*ទៅកន្លែងមួយទៀតជាមួយកងទ័ពវៀតណាម ។ បន្ទាប់មក លោកត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលកុមារកំព្រា ។ តាំងពីពេលនោះមក លោកមិនដែលបានជួបមុខឪពុកម្តាយជាថ្មីម្តងទៀតទេ ។*

***ហ៊ឹម ហ៊ុយ*** **:** *លោកគឺជាអតីតអ្នកយាមនៅមន្ទីរស-២១ ។ លោកបាននិយាយពីបទពិសោធន៍របស់លោកតាំងពីមុនរហូតមកដល់សម័យខ្មែរក្រហម ។ លោកត្រូវបានជ្រើសរើសឲ្យចូលបម្រើក្នុងជួរកងទ័ពនៅឆ្នាំ១៩៧៣ ។ ពេលលោកមកដល់ស្រុក១៨ លោកត្រូវបានស្នើឲ្យទៅចូលរៀនវគ្គសិក្សានយោបាយ ។ លោកបាននិយាយថា លោកនឹកផ្ទះខ្លាំងណាស់ពេលលោកសិក្សានៅទីនោះ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យលោកមកលេងផ្ទះទេ ។ អាមេរិកបានទម្លាក់គ្រាប់បែកជិតកន្លែងដែលលោករៀនសូត្រពីរដងក្នុងមួយថ្ងៃ ។ ហើយកម្មាភិបាលនៅទីនោះបានប្រាប់គាត់ថា ប្រសិនបើមានការទម្លាក់គ្រាប់បែកម្តងទៀត លោកអាចស្លាប់ ។ បន្ទាប់មក លោកត្រូវបានបញ្ជូនទៅខេត្តតាកែវ ប៉ុន្តែលោកធ្លាក់ខ្លួនឈឺ ហើយត្រូវបាននាំយកទៅមន្ទីរពេទ្យ ។ លោកបានលួចទៅលេងផ្ទះបីថ្ងៃ ។ លោកបានជម្រាបប្រាប់សិក្ខាកាមទាំងអស់ថា លោកធ្វើការបម្រើនៅក្នុងជួរកងទ័ពរហូតដល់ឆ្នាំ១៩៧៦ ។ នៅចុងឆ្នាំ១៩៧៦ លោកត្រូវបានបញ្ជូនឲ្យទៅធ្វើទាហានជើងទឹក ។ នៅឆ្នាំ១៩៧៧ មេៗនៅក្នុងកងពលលេខ៧ជាច្រើនត្រូវបានចាប់ខ្លួន ។ ក្រោយមក លោកត្រូវបានដំឡើងជាប្រធានកងវរយនៅមន្ទីរស-២១ មានភារកិច្ចនាំអ្នកទោសទៅដើរឯក ។ លោកបាននិយាយថា បុគ្គលិកគុកទួលស្លែងជាច្រើនត្រូវបានចាប់ខ្លួន ហើយឈ្មោះរបស់លោកក៏មាននៅក្នុងបញ្ជីដែរ ។*

*សំណួរពីសិក្ខាកាមរួមមាន :*

*១- លោកនិយាយថា លោកធ្វើការនៅក្នុងកងចាប់ចង ។ ខ្ញុំចង់ដឹងថា បើសិនមានមនុស្សមិនព្រមឲ្យចាប់ តើលោកវាយពួកគេដែរទេ?*

*២- តើលោកមានស្រុកកំណើតនៅឯណា ហើយលោកមានអាយុប៉ុន្មាន?*

*៣- តើស្រុក១៨មានន័យដូចម្តេច?*

*៤- តើលោកអាចប្រាប់យើងអំពីលេខកូដរបស់ស្រុក១៨បានឬទេ?*

*៥- លោកគឺជាយុវជនវ័យក្មេងនៅមន្ទីរស-២១ ហើយត្រូវតែមានមិត្តភក្តិ ។ លោកមិនមែនកើតចេញពីគ្រួសារឃាតករទេ ។ ពេលដែលលោកឃើញក្មេងៗត្រូវគេសម្លាប់ តើលោកគិតអ្វីទៅ? តើលោករស់នៅកន្លែងមួយ ដែលកូនក្មេងត្រូវបានសម្លាប់ដោយរបៀបណា?*

**ចម្លើយ :** *ខ្ញុំមិនដែលបានសប្បាយចិត្តអំពីតួនាទីរបស់ខ្ញុំនៅមន្ទីរស-២១ទេ ។ ថ្ងៃមួយ នៅខែមេសា ឆ្នាំ១៩៧៧ ខ្ញុំបានសុំ សុន សេន ដើម្បីផ្លាស់ខ្ញុំទៅសមរភូមិ ហើយឲ្យខ្ញុំបានចេញ*

ផុតពីមន្ទីរស-២១ ។ ថ្ងៃនោះ សុន សេន បានសួរខ្ញុំថា "មិត្តឯងហ៊ានវ៉ៃយួនទេ?" ពួកគេខ្លាចថា ប្រសិនបើយួនចាប់ខ្ញុំបាន ការសម្ងាត់នៅមន្ទីរស-២១ នឹងត្រូវបែកការណ៍ ។ ខ្ញុំព្រួយបារម្ភថា ប្រសិនបើខ្ញុំត្រូវចាប់ខ្លួន គ្រួសារខ្ញុំទាំងអស់ក៏នឹងត្រូវចាប់ខ្លួនដែរ ។

ចំពោះក្មេងៗ ខ្ញុំមិនដែលបានធ្វើយ៉ាងដូច្នេះទេ ។ បរិយាកាសនៅឆ្នាំ១៩៧៧ មិនទាន់តឹងតែងខ្លាំងទេ ។ កម្មាភិបាលអាចនិយាយជាមួយមនុស្សនៅតាមកងផ្សេងៗបាន ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៨ បរិកាសនៃភាពមិនទុកចិត្តគ្នាកាន់តែជ្រៅទៅៗ ។ អ្នកទាំងអស់គិតតែពីខ្លួនឯងប៉ុណ្ណោះ ។ មកត្រឹមដំណាក់កាលនេះ មនុស្សស្ទើរតែទាំងអស់ត្រូវបានចាប់ខ្លួន ហើយមិនមានអ្នកណាម្នាក់អាចធ្វើអ្វីបានឡើយ ។ ខ្ញុំប្រហែលជាស្លាប់ បើសិនជាកងទ័ពវៀតណាមមិនបានមកដល់ទាន់ពេលទេនោះ ។ នៅក្នុងកងពល៧០៣ ដែលជាអង្គភាពខ្ញុំធ្លាប់ធ្វើការ កម្មាភិបាលភាគច្រើនមកពីកងពលនេះត្រូវបានសម្លាប់ ។

៦- តើលោកចាប់អារម្មណ៍យ៉ាងដូចម្តេចចំពោះការកាត់ទោស ឌុច មកដល់ពេលនេះ? តើលោកគិតយ៉ាងដូចម្តេចដែរ ចំពោះអ្វីដែល ឌុច បាននិយាយកន្លងមក?

**ចម្លើយ** : ខ្ញុំសប្បាយមែនទែន ពេលដែល ឌុច ត្រូវបានកាត់ទោស ។ នៅជំនាន់ខ្មែរក្រហម ឌុច និង ហ៊ី អត់ត្រូវគ្នាទេ ។ ឌុច ចូលចិត្តកម្មាភិបាលមកពីខាងភូមិភាគបស្ចិម ។ នៅក្នុងពេលនោះ ខ្លួនខ្ញុំមានបំណងទម្លាយគុក ។ ខ្ញុំគិតថា ហ៊ី នឹងគាំទ្រគំនិតខ្ញុំដែរ ។ ប៉ុន្តែការទម្លាយគុកមិនបានសម្រេចទេ ពីព្រោះ ហ៊ី មិនបានយល់ព្រមធ្វើតាមខ្ញុំ ។ ខ្ញុំមានពិសោធន៍អំពីកន្លែងនោះនៅគិរីរម្យ ។ ខ្ញុំបានដឹងថា ទីនោះគឺជាមូលដ្ឋានទ័ពរបស់ លន់ នល់ ដែលអាចឲ្យយើងគេចខ្លួនបាន ។ ខ្ញុំមិនមែនជាមនុស្សអាក្រក់ទេ ។ បន្ទាប់ពីរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឃើញទាហាន លន់ នល់ ប៉ុន្តែខ្ញុំមិនបានសម្លាប់ពួកគេឡើយ ។ ខ្ញុំអាចសម្លាប់ពួកគេបាន ។ ប៉ុន្តែ ខ្ញុំមិនមែនជាមនុស្សអាក្រក់ទេ ។

**ឆាំង យុ** : លោកគឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានជម្រាបជូនសិក្ខាកាមទាំងអស់អំពីសកម្មភាពផ្សេងៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាការអប់រំពីអំពើប្រល័យពូជសាសន៍ ការងារស្រាវជ្រាវ ការសាងសង់មជ្ឈមណ្ឌលអចិន្ត្រៃយ៍ និងដំណើរការវិវឌ្ឍន៍របស់សាលាក្តីខ្មែរក្រហម ។ លោកក៏បានចែកជូនសិក្ខាកាមនូវ គម្រោងយុទ្ធសាស្រ្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ឆ្នាំបន្តបន្ទាប់ទៀត និងទស្សនាវដ្តី*ស្វែងរកការពិត* ។

***សូ ហ្វារីណា*** ៖ កញ្ញាគឺជាប្រធានក្រុមនៃគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ឥស្លាម និងជានិស្សិតថ្នាក់អនុបណ្ឌិត នៅសកលវិទ្យាល័យអូហាយយ៉ូ សហរដ្ឋអាមេរិក ។ កញ្ញាបានអធិប្បាយអំពីតួនាទីរបស់កញ្ញានៅក្នុងគម្រោងនេះ ។ កញ្ញាបានមានប្រសាសន៍ថា គម្រោងនេះចាប់ផ្តើមដំណើរការតាំងពីខែកញ្ញា ឆ្នាំ២០០៥ ។ កញ្ញាបានពន្យល់ទៅសិក្ខាកាមថា គោលបំណងរបស់គម្រោងគឺ ដើម្បីប្រមែប្រមូលព័ត៌មានអំពីសហគមន៍ជនជាតិចាម និងឲ្យពួកគាត់និយាយអំពីអ្វីដែលបានកើតនៅក្នុងរបបខ្មែរក្រហម ។ កញ្ញាក៏បាននិយាយអំពីគម្រោងផ្សព្វផ្សាយដល់សហគមន៍ឥស្លាម ដូចជាការអញ្ជើញមេដឹកនាំសាសនាឥស្លាមមកទីក្រុងភ្នំពេញ ក៏ដូចជាដំណើរទស្សនកិច្ចមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីចូលជួបសំណេះសំណាលជាមួយសហគមន៍ឥស្លាមផ្សេងទៀតនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## ឃ. សកម្មភាពមើលឃើញដោយផ្ទាល់ និង ដំណើរទស្សនកិច្ច

ខ្សែភាពយន្ត សេចក្តីដកស្រង់ចេញពីការសម្តែង និងចម្រៀងក៏ត្រូវបានបញ្ចូលនៅក្នុងវគ្គបណ្តុះបណ្តាលនេះដែរ ។ មានការពិភាក្សា បន្ទាប់ពីបញ្ចប់សកម្មភាពទាំងអស់នេះរួចមក ។

**ការបញ្ចាំងខ្សែភាពយន្តអំពី “គុកទួលស្លែង និង គុកបរិតនៅខេត្តព្រៃវែង ក្នុងឆ្នាំ១៩៧៩”**

ខ្សែភាពយន្តទាំងពីរនេះ ត្រូវបានបញ្ចាំងនៅព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ។ ខ្សែភាពយន្តដែលមិនមានសំឡេងនិងដ៏កម្រនេះ បានបង្ហាញពីចក្ខុសក្ខីកម្មដ៏គួរឲ្យចាប់អារម្មណ៍ នៃរយៈកាលបន្ទាប់ពីវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ ។ លោកស្រីសាស្ត្រាចារ្យ ឡូរ៉ា សាំម័រ ជាអ្នកសម្របសម្រួលការពិភាក្សាទៅលើខ្សែភាពយន្តទាំងពីរនេះ ។ លោកស្រីបានប្រាប់ដល់សិក្ខាកាមថា រាល់ពេលមានការបញ្ចាំងភាពយន្ត អ្នកទស្សនាត្រូវសួរខ្លួនឯងបីសំណួរ ៖

១- តើនរណាជាអ្នកផលិតខ្សែភាពយន្តនេះ?

២- តើនរណាជាទស្សនិកជនគោលដៅ?

៣- តើខ្សែភាពយន្តនេះចង់បង្ហាញអំពីអ្វី?

បន្ទាប់មក លោកស្រីពណ៌នាសង្ខេបទៅលើខ្សែភាពយន្តទាំងពីរ ដោយឆ្លើយទៅនឹងសំណួរដែលលោកស្រីបានលើកឡើង ។ លោកស្រីបានពន្យល់ថា ខ្សែភាពយន្តមួយចំនួនគឺសម្រាប់ទុកជាឯកសារ មិនមែនសម្រាប់បញ្ចាំងឲ្យសាធារណជនទស្សនានោះទេ ហើយមួយចំនួនទៀតគឺសម្រាប់បញ្ចាំងតាមទូរទស្សន៍វៀតណាម ។

លោកស្រីបានអះអាងថា ខ្សែភាពយន្តទាំងនេះមិនបានបង្រៀនអ្វី អំពីជម្លោះរវាងកម្ពុជានិងវៀតណាមនោះទេ ។ លោកស្រីក៏បានថ្លែងដែរថា ភ័ស្តុតាងជាខ្សែភាពយន្តមិនបានជួយយើងក្នុងការ

ត្រិះរិះពិចារណា និងចំណេះដឹងខាងប្រវត្តិសាស្ត្រទេ ប៉ុន្តែយើងត្រូវតែប្រុងប្រយ័ត្នក្នុងការបកស្រាយឲ្យបានត្រឹមត្រូវទៅលើភ័ស្តុតាងដែលអាចមើលឃើញ ។

**ការច្រៀងចម្រៀង និង ការបញ្ចាំងខ្សែភាពយន្ត** ៖ ចម្រៀង "ឱភ្នំពេញអើយ1" ច្រៀងពេលកុមារស្ថិតនៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩ និងការសម្តែងល្ខោន"ទម្លាយភាពស្ងប់ស្ងាត់"

នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ សិក្ខាកាមបានចាប់ផ្តើមវគ្គបណ្តុះបណ្តាល ដោយទស្សនាខ្សែភាពយន្ត "កុមារកម្ពុជា និង ទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩" ។ ខ្សែភាពយន្តបានបង្ហាញពីការលំបាកវេទនា កុមារស្គមរីងរៃរស់នៅក្នុងខ្ទមបែកបាក់ដូចសំបុកកណ្តុរ ដែលបានដើរដឹកកកាយសំរាមដើម្បីរកម្ហូប ។ សម្លៀកបំពាក់រហែករយីរយ៉ៃ និងខ្លួនប្រាណកខ្វក់ បានរំលឹកពីភាពក្រីក្រនៃជីវិតរបស់កុមារ បន្ទាប់ពីរបបខ្មែរក្រហមកន្លងផុតទៅ ។ ក្នុងអំឡុងពេលនៃការបញ្ចាំងខ្សែភាពយន្ត កញ្ញា ជៀម ចាន់សុវណ្ណារី ច្រៀងបទ "ឱភ្នំពេញអើយ" ។

បន្ទាប់ពីទស្សនាខ្សែភាពយន្ត សិក្ខាកាមបានស្តាប់ចម្រៀងមួយបទទៀត ដែលដកស្រង់ចេញពីល្ខោនរឿង"ទម្លាយភាពស្ងប់ស្ងាត់" ។ លោក ឆាំង យុ បានដឹកនាំការពិភាក្សា ដោយឲ្យសិក្ខាកាមពន្យល់អំពីអត្ថន័យនៃបទចម្រៀង ហើយសួរទៅសិក្ខាកាមទាំងអស់ថា តើចម្រៀងមួយណាមានលក្ខណៈជាការផ្សះផ្សាជាតិជាង ។ ខាងក្រោមគឺជាយោបល់របស់សិក្ខាកាមៈ

"ចម្រៀងទីមួយបង្ហាញពីការខឹងសម្បា ប៉ុន្តែចម្រៀងទីពីរបានរំឭកឡើងវិញនូវពាក្យ"ទន្លេ" ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា និងទន្លេនៃការទទួលខុសត្រូវ ។ វាហាក់ដូចជាយើងប្តូរពីភាពទុក្ខសោកទៅជាការទទួលខុសត្រូវ ។ ចម្រៀងនេះមានអត្ថន័យល្អជាង ប៉ុន្តែចម្រៀង "ឱភ្នំពេញអើយ" គឺចេញពីទុក្ខសោកទៅការសង្ឃឹក" ។

"ខ្ញុំគិតថា ចម្រៀងទាំងពីរមានអត្ថន័យល្អដូចគ្នា ប៉ុន្តែ ចម្រៀងទីពីរមានអត្ថន័យល្អជាង ។ ចម្រៀងទីមួយហាក់ដូចជាផ្តោតតែទៅលើទីក្រុងភ្នំពេញ ហើយមិនបាននិយាយអំពីកន្លែងផ្សេងៗទៀត ដែលប្រជាជនបានធ្វើដំណើរទៅ បន្ទាប់ពីរបបខ្មែរក្រហម ។ ចម្រៀងទីពីរនិយាយអំពីការផ្សះផ្សា និងប្រែក្លាយពីការសម្លាប់ទៅជាការផ្សះផ្សា" ។

"ចម្រៀងទាំងពីរមានសារៈសំខាន់ដូចគ្នា ពីព្រោះវាបានរំឭកយើងនូវអ្វីដែលបានកើតឡើង ។ ចម្រៀងទីមួយបានរំឭកខ្ញុំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ចម្រៀងនេះមានមនោ

*សញ្ចេតនាណាស់សម្រាប់ខ្ញុំ ហើយខ្ញុំមិនអាចទប់ទឹកភ្នែករបស់ខ្ញុំបានទេ ។ ចម្រៀងទីពីរក៏មានអត្ថន័យល្អដែរ ។ បន្ទាប់ពីខ្ញុំបានស្តាប់ ខ្ញុំមានអារម្មណ៍ធូរស្បើយឡើងវិញ» ។*

*«ខ្ញុំគិតថាចម្រៀងទីមួយបរិយាយអំពីការរស់រានមានជីវិត គឺជាជីវិតទីពីររបស់យើងទាំងអស់គ្នា ។ ហើយចម្រៀងទីពីរលើកទឹកចិត្តដល់យើង ឲ្យបេះដូងរបស់យើងរក្សានិងព្យាបាលរបួសផ្លូវចិត្ត» ។*

*«ខ្ញុំគិតថា យើងមិនគួរវាយតម្លៃអំពីអត្ថន័យនៃចម្រៀងនីមួយៗនោះទេ ។ យើងមិនអាចប្រៀបធៀបចម្រៀងមួយទៅចម្រៀងមួយទៀតបានឡើយ ។ យើងគួរតែគិតអំពីពេលវេលាដែលចម្រៀងទាំងពីរនេះត្រូវបានតែងឡើង ។ ចម្រៀងទីមួយគឺអំពីអតីតកាល ហើយចម្រៀងទីពីរគឺអំពីបច្ចុប្បន្នកាល ។ ចម្រៀងទីមួយត្រូវបានសរសេរឡើងក្នុងអំឡុងពេលសង្គ្រាម ។ ដូច្នេះ វាពិបាកនឹងចៀសឲ្យផុតពីពាក្យសង់សឹកណាស់» ។*

## ដំណើរទស្សនៈកិច្ចទៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និង ជើងឯក

*នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ គ្រូបង្គោលថ្នាក់ជាតិបានចូលរួមក្នុងដំណើរទស្សនាទៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក ។ បន្ទាប់ពីដំណើរទស្សនកិច្ច យើងបានបើកការពិភាក្សាអំពីសារៈសំខាន់នៃដំណើរទស្សនកិច្ច និងថាតើដំណើរទស្សនកិច្ចនេះ អាចត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការសិក្សានៅតាមសាលាដែរឬទេ ។ ខាងក្រោមគឺជាយោបល់មួយចំនួនពីសិក្ខាកាម ៖*

*ពេលខ្ញុំឃើញសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាបានធ្វើឲ្យខ្ញុំជឿថា អ្វីៗពិតជាបានកើតឡើងមែន ។ ពេលយើងបង្រៀនសិស្សនៅក្នុងថ្នាក់ យើងគួរតែប្រើប្រាស់ដំណើរទស្សនកិច្ចដើម្បីឲ្យសិស្សមានការជឿជាក់» ។*

*«ប្រសិនបើសិស្សបានទៅទស្សនាទីតាំងទាំងនោះ វាអាចធ្វើឲ្យសិស្សមានអារម្មណ៍មិនល្អនិងសោកសៅ ហើយនិងចង់ចាំឬស្រមើស្រមៃអំពីអ្វីដែលបានកើតឡើង» ។*

*ពេលដែលយើងធ្វើដំណើរទស្សនកិច្ច យើងនឹងជំរុញឲ្យមានការអប់រំ ពីព្រោះយោធាក្មេងៗរបស់ខ្មែរក្រហមទាំងនោះមិនបានរៀនសូត្រទេ ។ ពេលអ្នកទទួលបានការអប់រំ អ្នកនឹងមិនអនុញ្ញាតិឲ្យនរណាម្នាក់គ្រប់គ្រងលើអ្នកទេ ។ ដូច្នេះការនាំសិស្សមកទស្សនានិងស្វែងយល់កន្លែងទាំងនេះ និងការនាំសិស្សមកមើលរូបថតក្មេងៗដែលមិនបានទទួលការអប់រំ នឹងជំរុញលើកទឹកចិត្តដល់សិស្សឲ្យទៅសាលារៀន និងប្រឹងប្រែងរៀនសូត្រ» ។*

## ល្ខោន«ទម្លាយភាពស្ងប់ស្ងាត់»

ឈុតមួយនៅក្នុងរឿង«ទម្លាយភាពស្ងប់ស្ងាត់» ត្រូវបានលើកយកមកសម្តែងជូនសិក្ខាកាមទាំងអស់ទស្សនា ។ ឈុតមួយដែលត្រូវបានលើកយកមកសម្តែង បង្ហាញពីការនិយាយគ្នារវាងជនរងគ្រោះនិងជនដៃដល់ ។

សិក្ខាកាមម្នាក់បានផ្តល់យោបល់ទៅលើការសម្តែងដូចខាងក្រោម ៖

> ទស្សនាការសម្តែងនេះ បានធ្វើឲ្យខ្ញុំនឹកឃើញអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ខ្មែរក្រហមបានឲ្យខ្ញុំកាប់ព្រៃ ។ ថ្ងៃមួយ ពេលដែលខ្ញុំទៅកាប់ព្រៃ ខ្ញុំបានធ្វើឲ្យបាក់កាំបិត ។ ខ្មែរក្រហមបានដាក់ពិន័យខ្ញុំ ។ ខ្ញុំបានរងរបួសហើយបានទៅព្យាបាលនៅមន្ទីរពេទ្យ ។ ខ្ញុំបានជួបជាមួយបុគ្គលិកពេទ្យម្នាក់ ហើយនារីពេទ្យនោះបានឲ្យខ្ញុំហូបបបរ ទោះជាខ្ញុំមិនចង់ហូបក៏ដោយ ។ បុគ្គលិកពេទ្យតូចតាចម្នាក់បានជួយយកអាសាខ្ញុំ ពេលខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យនោះ» ។

នៅពេលសួរថា តើអាចយកការសម្តែងនេះទៅបង្រៀនប្រវត្តិសាស្ត្របានដែរឬទេ គ្រូបង្គោលថ្នាក់ជាតិជាច្រើនមានការស្ទាក់ស្ទើរ ហើយបានផ្តល់យោបល់មួយចំនួនដូចខាងក្រោម ៖

> «យើងចាំបាច់ត្រូវតែមានវិធីសាស្ត្រក្នុងការសម្តែង» ។
> «ការសម្តែងបែបនេះ គួរតែប្រើនៅក្នុងថ្នាក់សិល្បៈ មិនមែនថ្នាក់ប្រវត្តិសាស្ត្រទេ» ។

លោកសាស្ត្រាចារ្យ ហ្វ្រេង ឆក បានជំរុញលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ថា គ្រូត្រូវតែធ្វើការផ្លាស់ប្តូរ ខណៈពេលដែលពិភពលោកមានការផ្លាស់ប្តូរ ហើយបានចាប់ផ្តើមទទួលយកនិងប្រើប្រាស់បច្ចេកវិទ្យា ។ គ្រូត្រូវតែទទួលយកនូវភាសាដែលសិស្សប្រើ ។

## ៦. ភាពខ្លាំង

**១-ការសិក្សានៅក្នុងក្រុមតូចៗ** ៖ ប្រសិនបើមានការមិនពេញចិត្ត ឬមានការខឹងសម្បានៅក្នុងក្រុមធំ បញ្ហាទាំងអស់នេះនឹងបាត់ទៅវិញ ពេលដែលសិក្ខាកាមប្រមូលផ្តុំគ្នានៅក្នុងក្រុមតូចៗ ។ សិក្ខាកាមដែលព្យាយាមបង្ហាញអំពីចំណេះដឹងរបស់ខ្លួននៅក្នុងក្រុមធំ ហាក់ដូចជាមិនសូវនិយាយស្តីនៅក្នុងក្រុមតូចៗ ។ បរិយាកាសស្និទ្ធស្នាលអនុញ្ញាតឲ្យសិក្ខាកាមមានសំឡេង ឬមានឱកាសលើកឡើងនូវបញ្ហាដោយមិនធ្វើឲ្យប៉ះពាល់ដល់ក្រុមទាំងមូល ។ ក្រុមតូចៗត្រូវបានអនុញ្ញាតឲ្យសិក្ខាកាមមានឱកាសឡើងបង្រៀនជាគំរូ ហើយផ្តល់យោបល់កែលម្អទៅលើកិច្ចតែងការបង្រៀនរបស់សិក្ខាកាមម្នាក់ៗ ។ បន្ទាប់

ពីទទួលបានយោបល់កែលម្អពីសមាជិកនៅក្នុងក្រុមនិងអ្នកសម្របសម្រួល សិក្ខាកាមទទួលបានការយល់ដឹងនិងការរំពឹងទុកច្រើនជាងមុន ។ សកម្មភាពនេះមានប្រយោជន៍សម្រាប់អ្នកសង្កេត ក្នុងការវាយតម្លៃការយល់ដឹងទៅលើវិធីសាស្ត្រក្នុងការបង្រៀន និងទៅលើសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

**២-ចម្រៀង ភាពយន្ត និងការសម្តែងល្ខោន** : សកម្មភាពទាំងនេះផ្តល់ជាវេទិកាមួយដែលអនុញ្ញាតឲ្យសិក្ខាកាមពិភាក្សាទៅលើប្រធានបទផ្សេងៗទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយប្រើប្រាស់សិល្បៈ អ្នកសម្របសម្រួលបានបង្កើតឲ្យមានបរិយាកាសស្វាគមន៍ល្អ ជាមួយសិក្ខាកាម ។ ការចាប់ផ្តើមការសិក្សានាពេលព្រឹក ដោយការបញ្ចាំងខ្សែភាពយន្តឬច្រៀងចម្រៀង គឺជាវិធីដ៏ល្អមួយក្នុងការទាក់ទាញការយកចិត្តទុកដាក់របស់សិក្ខាកាម និងផ្តល់សកម្មភាពទាក់ទង សម្រាប់ចាប់ផ្តើមការសិក្សា ។

**៣-វាគ្មិន** : ដូចសកម្មភាពដែលប្រើប្រាស់សិល្បៈជាមូលដ្ឋានដែរ បទបង្ហាញរបស់វាគ្មិនគឺជាវិធីសាស្ត្រដ៏មានប្រយោជន៍ក្នុងការបង្កើតឲ្យមានការពិភាក្សា និងបង្កើនការយល់ដឹងរបស់សិក្ខាកាម ។ សិក្ខាកាមក៏ពេញចិត្តចំពោះការពិភាក្សាដ៏វែង បន្ទាប់ពីវាគ្មិនបានបញ្ចប់បទបង្ហាញរួចមក ។ សិក្ខាកាមទាំងអស់រីករាយនឹងការសិក្សាដែលមានការសួរដេញដោលទៅវិញទៅមក ជាមួយវាគ្មិនជាតិនិងអន្តរជាតិ ។

**៤-ការឡើងបង្រៀនគំរូ** : នៅក្នុងក្រុមតូចៗនីមួយៗសិក្ខាកាមគ្រប់រូបត្រូវតែឡើងបង្រៀនជាគំរូបង្ហាញដល់គ្រូដែលជាសិក្ខាកាមនៅក្នុងក្រុមរបស់ខ្លួន ។ សកម្មភាពនេះផ្តល់វេទិកាដ៏ល្អមួយសម្រាប់សិក្ខាកាមទាំងអស់ ក្នុងការសិក្សាឲ្យស៊ីជម្រៅទៅលើសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅប្រវត្តិសាស្ត្រ ។ សិក្ខាកាមមួយចំនួនបានងាកចេញពីសៀវភៅណែនាំ ហើយបន្ថែមវិធីសាស្ត្រផ្ទាល់ខ្លួនដើម្បីសម្រេចឲ្យបាននូវវត្ថុបំណងនៃមេរៀនរបស់ខ្លួន ។ សិក្ខាកាមមួយចំនួនទៀតអនុវត្តតាមសៀវភៅណែនាំទាំងស្រុង ។ ទោះជាប្រើវិធីសាស្ត្រមួយណាក៏ដោយ ការឡើងបង្រៀនមេរៀនគំរូគឺជាវិធីដ៏ល្អមួយដើម្បីឲ្យសិក្ខាកាមចេះប្រើប្រាស់សម្ភារៈឧបទេស ។

**៥-ការដោះស្រាយទៅនឹងការខ្វល់ខ្វាយដែលសិក្ខាកាមលើកឡើង** : លោក ឌី ខាំបូលី និងអ្នកសម្របសម្រួលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ បានធ្វើកិច្ចការយ៉ាងល្អក្នុងការដោះស្រាយនូវរាល់បញ្ហាដែលសិក្ខាកាមបានលើកឡើង ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និយាយទៅកាន់គ្រូបង្គោលថ្នាក់ជាតិដោយភាសាគោរព ដូចជាពាក្យ«លោកគ្រូអ្នកគ្រូ» និងនិយាយប្រកបដោយសម្តីទន់ភ្លន់ ។ កាយវិការបែបនេះមានន័យថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្តែងការគោរពខ្ពស់ចំពោះគ្រូបង្គោលថ្នាក់ជាតិ ។ សហអ្នកនិពន្ធសៀវភៅណែនាំសម្រាប់គ្រូបង្រៀន គឺបណ្ឌិត ដា ផល្លា និងលោក គ្រីស ឌៀរីង បានធ្វើកិច្ចការយ៉ាងល្អក្នុងការរក្សាកម្មវិធីឲ្យទៅតាមពេលវេលា ដែលបាន

កំណត់ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សេងទៀត បានជួយកែសម្រួលការបកប្រែគ្នាទៅវិញទៅមក ដែលបង្ហាញពីការធ្វើការនៅក្នុងក្រុមបានយ៉ាងល្អ ។

**៦-គំរូវគ្គសិក្សាប្រហាក់ប្រហែលទៅនឹងគំរូនៅក្នុងថ្នាក់** ៖ វិធីដែលយើងអនុវត្តវគ្គបណ្តុះបណ្តាលនេះ គឺជាវិធីដែលអាចយកទៅអនុវត្តនៅក្នុងថ្នាក់រៀន ។ វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិមានរួមបញ្ចូលការឡើងបង្ហាញរបស់វាគ្មិន ចម្រៀង ខ្សែភាពយន្ត មេរៀនផ្អែកលើការពិត និងសំណួរត្រិះរិះពិចារណា ។

## ៧. ឧបសគ្គ

បញ្ជីរាយចំណុចឧបសគ្គខាងក្រោម សង្ខេបពីកិច្ចប្រជុំដែលធ្វើឡើងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកជំនាញអន្តរជាតិ និងអ្នកសម្របសម្រួល បានចូលរួមនៅក្នុងអង្គប្រជុំនេះ ។

**១. វត្ថុបំណងមិនច្បាស់លាស់** ៖ វាហាក់ដូចជា យើងមិនបានផ្តល់វត្ថុបំណងឲ្យបានច្បាស់លាស់ជូនដល់គ្រូបង្គោលថ្នាក់ជាតិទាំងអស់ ក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល ។ គ្រូបង្គោលថ្នាក់ជាតិហាក់ដូចជាមានភាពស្រពេចស្រពិលចំពោះតួនាទីរបស់ខ្លួន និងមូលហេតុនៃការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ។ គ្រូបង្គោលថ្នាក់ជាតិ ហាក់ដូចជាមិនទទួលបានព័ត៌មានច្បាស់លាស់ អំពីតួនាទីរបស់ខ្លួនសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ។

**អនុសាសន៍** ៖ សម្រាប់វគ្គបណ្តុះបណ្តាលលើកក្រោយ យើងត្រូវរៀបចំជាអត្ថបទព័ត៌មានខ្លីមួយដែលបង្ហាញពីគោលបំណងនៃវគ្គបណ្តុះបណ្តាល ។ យើងគួរបិទក្រដាសព័ត៌មានអំពីគោលបំណងនិងវត្ថុបំណងនៅខាងមុខបន្ទប់ ជាការក្រើនរំឭកដល់អ្នកចូលរួមទាំងអស់ ។ យើងក៏គួរធ្វើសកម្មភាពឈប់សម្រាករយៈពេលខ្លី ដើម្បីឲ្យគ្រូបង្គោលថ្នាក់ជាតិមានពេលរៀបរាប់ពីវត្ថុបំណងនិងគោលបំណង សម្រាប់វគ្គបណ្តុះបណ្តាល ក៏ដូចការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ការធ្វើបែបនេះអាចជួយសម្រួលដល់ការយល់ដឹង អនុញ្ញាតឲ្យមានការបង្កើតឡើងនូវការរំពឹងទុក និងផ្តល់សំឡេងដល់គ្រូបង្គោលថ្នាក់ជាតិនៅក្នុងការរៀបចំនិងលទ្ធផលនៃវគ្គបណ្តុះបណ្តាល ។

**២. ការអនុវត្តមេរៀនគំរូមិនដូចគ្នា** ៖ យើងបានកត់សម្គាល់ឃើញថា គ្រូបង្គោលថ្នាក់ជាតិមិនទទួលបាននូវការអនុវត្តមេរៀនគំរូដូចៗគ្នាទេ ។ ទោះបីជាក្រុមតូចៗបានផ្តល់ឱកាសឲ្យគ្រូបង្គោលថ្នាក់ជាតិប្រើប្រាស់សៀវភៅណែនាំនិងសម្ភារៈឧបទេសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏គ្រូបង្គោល

ថ្នាក់ជាតិមិនទទួលបាននូវមេរៀនគំរូមួយ ដែលមានបទដ្ឋានដូចៗគ្នាដែរ ។ អ្នកសម្របសម្រួលនៅក្នុងក្រុមតូចៗ ជាញឹកញយបានងាកចេញពីសៀវភៅណែនាំ ហើយធ្វើការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗរៀងៗខ្លួន ។ អ្នកសម្របសម្រួលខ្លះផ្ដល់យោបល់កែលម្អភ្លាមៗបន្ទាប់ពីមេរៀននីមួយៗ ហើយមួយចំនួនទៀតផ្ដល់យោបល់កែលម្អ បន្ទាប់ពីការអនុវត្តមេរៀនគំរូក្នុងរយៈពេលមួយថ្ងៃ ។ អ្នកសម្របសម្រួលមួយចំនួនធ្វើកិច្ចតែងការបង្រៀនលម្អិត ហើយមួយចំនួនទៀតមិនបានរៀបចំឲ្យបានលម្អិតទេ ។ ជាចុងក្រោយ យើងសង្កេតឃើញថា ពុំមានភាពស៊ីគ្នានៅក្នុងវិធីសាស្ត្របង្រៀនក្នុងការឡើងអនុវត្តមេរៀនគំរូទេ ។ អ្នកសម្របសម្រួលខ្លះ ផ្អាកការអនុវត្តមេរៀនគំរូនៅពាក់កណ្ដាលផ្លូវ ដើម្បីទុកពេលឲ្យសិស្សសួរ ខណៈពេលដែលអ្នកខ្លះទៀតកំពុងអនុវត្តមេរៀនគំរូ ហាក់ដូចជាខ្លួនកំពុងតែបង្រៀននៅក្នុងថ្នាក់ ។

**អនុសាសន៍** ៖ អ្នកសម្របសម្រួលនិងគ្រូបង្គោលថ្នាក់ជាតិ អាចអនុវត្តមេរៀនគំរូនៅក្នុងក្រុមតូចៗ ឬក្រុមធំតែមួយ ។ អ្នកសម្របសម្រួលគួរតែជួបគ្នាមួយថ្ងៃមុនដើម្បីធានាឲ្យបានថា កិច្ចតែងការបង្រៀនរបស់ខ្លួនមានភាពប្រាកដប្រជា និងដើម្បីធានាឲ្យបានថា អ្នកសម្របសម្រួលទាំងអស់ដើរតាមគោលការណ៍ដែលបានកំណត់ ។ ធ្វើដូច្នេះ ព័ត៌មានដែលបង្ហាញជូនដល់ក្រុមតូចៗនីមួយៗមានភាពដូចគ្នាទាំងអស់ ។

៣. ***ភាពតានតឹងរវាងការបង្រៀននិងការរៀនប្រវត្តិសាស្ត្រ*** ៖ វាហាក់ដូចជាមានភាពតានតឹងរវាងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រនេះ ។ និយាយម្យ៉ាងទៀត វិធីសាស្ត្រក្នុងការបង្រៀនស្ថិតនៅជួរខាងក្រោយ បើប្រៀបធៀបទៅនឹងមេរៀនប្រវត្តិសាស្ត្រនិងការពិតពីប្រវត្តិសាស្ត្រ ។ ឧទាហរណ៍ មេរៀនអំពីប្រវត្តិសាស្ត្រតែងតែបន្តហួសដល់ម៉ោងសម្រាប់មេរៀនអំពីវិធីសាស្ត្រនិងគរុកោសល្យ ។ គ្រូបង្គោលថ្នាក់ជាតិក៏បានចំណាយពេលច្រើនពិភាក្សាអំពីប្រវត្តិសាស្ត្រ ។

**អនុសាសន៍** ៖ សម្រាប់វគ្គបណ្ដុះបណ្ដាលលើកក្រោយ អ្នកសម្របសម្រួលគួរព្យាយាមរក្សាការពិភាក្សានិងសំណួរ ឲ្យស្ថិតនៅក្នុងវង្វង់នៃសៀវភៅប្រវត្តិសាស្ត្រ ជាជាងការពិភាក្សាបែកឆ្ងាយពីវត្ថុបំណង ។ គ្រូបង្គោលថ្នាក់ជាតិគួរត្រូវបានបញ្ជាក់ឲ្យច្បាស់ថា ខ្លួនមិនមែនចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនេះ ដើម្បីក្លាយទៅជាអ្នកជំនាញខាងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែដើម្បីឲ្យគ្រូបង្គោលថ្នាក់ជាតិទាំងអស់ មានលទ្ធភាពសមល្មមក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅសិស្សថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ ។ ជាការពិតណាស់ គ្រូបង្គោលថ្នាក់ជាតិគួរមានពេលវេលាក្នុងការ

*សួរនិងឆ្លើយទៅនឹងសំណួរក្នុងកំឡុងពេលនៃការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រ ប៉ុន្តែសំណួរត្រូវតែមានដែនកំណត់ ។ ប្រសិនបើគ្រូបង្គោលថ្នាក់ជាតិ ចង់សួរសំណួរដែលមិនជាប់ទាក់ទងទៅនឹងចំណុចនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ឬមិនមានពេលសួរសំណួរដោយសារអស់ម៉ោង គ្រូបង្គោលថ្នាក់ជាតិអាចជួបជាមួយអ្នកប្រវត្តិសាស្ត្រ ឬអ្នកជំនាញបន្ទាប់ពីម៉ោងសិក្សា ឬក្នុងកំឡុងពេលអាហារថ្ងៃត្រង់ឬអាហារសម្រន់ ។*

***៨. វិធីសាស្ត្របង្រៀនបែបលោកខាងលិច និង វិធីសាស្ត្របង្រៀនរបស់កម្ពុជា*** *: វាមានភាពខុសគ្នារវាងវិធីសាស្ត្របង្រៀនរបស់លោកខាងលិច(សិស្សមជ្ឈមណ្ឌល) និងវិធីសាស្ត្របង្រៀនរបស់កម្ពុជា(សិស្សមជ្ឈមណ្ឌលនៅមានកម្រិត) ដែលគ្រូគឺជាអ្នកមានចំណេះដឹងលើគ្រប់អ្វីៗទាំងអស់ ហើយការពិតនៃ ប្រវត្តិសាស្ត្របានក្លាយទៅជាចំណុចសម្រេចនៃភាពជោគជ័យ ។ កម្ពុជាហាក់ដូចជាពេញចិត្តចំពោះវិធីសាស្ត្របែបនេះដាង ព្រោះវិធីសាស្ត្រនេះបានជួយដល់គ្រូក្នុងការគ្រប់គ្រងក្រុមធំៗ និងការពារអំណាចរបស់គ្រូ នៅពេលមានការចោទសួរពីសិស្ស ។ នៅក្នុងវិធីសាស្ត្រ«សិស្សមជ្ឈមណ្ឌល» ដំណើរការនៃការ សិក្សាគឺជាលទ្ធផលដែលយើងចង់បាន ជាជាងការផ្ទេរចំណេះដឹងពីគ្រូទៅសិស្ស ។ គ្រូត្រូវលើកទឹកចិត្តសិស្សឲ្យពិភាក្សាទៅលើគំនិតរបស់ខ្លួន មេរៀន និងព័ត៌មានដែលគ្រូផ្តល់ឲ្យ ។ នៅក្នុងករណីខ្លះ ការលើកទឹកចិត្តនេះ អាចនាំមកនូវទស្សនរបស់សិស្ស ដែលប្រឆាំងទៅនឹងជំហររបស់គ្រូទៅលើប្រធានបទមួយ ។ប្រសិនបើគ្រូមិនមានបទពិសោធន៍ អំពីវិធីក្នុងការដោះស្រាយបញ្ហានេះ គ្រូប្រហែលជានឹងមានអារម្មណ៍ថា ខ្លួនកំពុងតែត្រូវបានវាយប្រហារ ឬសិស្សមានការសង្ស័យចំពោះសមត្ថភាពរបស់ខ្លួនក្នុងនាមជាគ្រូបង្រៀនម្នាក់ ។ ទោះជាគ្រូបង្គោលថ្នាក់ជាតិមិនបានលើកឡើងពីបញ្ហានេះក៏ដោយ យើងមានអារម្មណ៍ថា គ្រូបង្គោលថ្នាក់ជាតិមានការព្រួយបារម្ភទៅលើការប្រើប្រាស់សំណួរទម្រង់បើក និងការពិភាក្សាបែប«សិស្សមជ្ឈមណ្ឌល» ។*

***អនុសាសន៍*** *: បញ្ហានេះមានលក្ខណប្រហាក់ប្រហែលទៅនឹងបញ្ហាដែលថាគម្រោងរបស់ប្រទេសលោកខាងលិចតែងតែអនុវត្តនូវបទដ្ឋានឬគោលដៅរបស់ខ្លួន នៅក្នុងសង្គមដែលមិនស្ថិតនៅក្នុងពិភពលោកខាងលិច ។ វាបានក្លាយទៅជាឧបសគ្គមួយនៃ«វិធីសាស្ត្ររបស់យើង» និង «វិធីសាស្ត្ររបស់គេ» ។ ទោះជាយ៉ាងនេះក្តី វាមានភាពប្រហាក់ប្រហែលគ្នាមួយចំនួនរវាងវិធីសាស្ត្របង្រៀនទាំងពីរ ហើយអ្នកសម្របសម្រួលត្រូវតែប្រើប្រាស់ភាពប្រហាក់ប្រហែលគ្នា ជាជាងផ្តោតទៅលើភាពខុសគ្នា ។ យើងគួរតែបញ្ជាក់ប្រាប់ទៅគ្រូបង្គោលថ្នាក់ជាតិថា វិធីសាស្ត្រ«កម្រិតនៃការគិត»* Taxonomy *នៅកម្ពុជា រួមមានសំណួរពិភាក្សានៅក្នុងជំហានទីបួនដល់ជំហានទីប្រាំមួយ ហើយយើងក៏ត្រូវការសំណួរពិភាក្សាផ្អែក*

*លើការពិតនៅក្នុងជំហានទីមួយដល់ជំហានទីបី ។ វគ្គបណ្តុះបណ្តាលនាពេលអនាគតគួរតែលើកឡើងអំពីវិធីសាស្ត្រ ក្របខ័ណ្ឌនៃការគិត របស់កម្ពុជានៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ យើងក៏អាចឲ្យគ្រូអានអត្ថបទមួយចំនួនដែលផ្អែកទៅលើទ្រឹស្តី ពួ។ នៅក្នុងក្រុម ។ នេះគឺជាវិធីរៀននៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មក យើងអាចឲ្យគ្រូស្វែងយល់ឲ្យកាន់តែស៊ីជម្រៅទៅលើអត្ថន័យ ដែលជាវិធីសាស្ត្របង្រៀនបែបលោកខាងលិច ។ បន្ទាប់ពីសកម្មភាពនេះ យើងអាចពន្យល់គ្រូបង្គោលថ្នាក់ជាតិទាំងអស់អំពីវិធីសាស្ត្រក្នុងការសួរសំណួរផ្អែកលើការពិត និងសំណួរផ្អែកលើការពិភាក្សា ។*

***៥. មិនមានការពិភាក្សាឲ្យបានទូលំទូលាយទៅលើសំណួរស្តីពីអំពើប្រល័យពូជសាសន៍*** *:* *យើងបានសង្កេតឃើញថា សំណួរទាក់ទងនឹងប្រវត្តិនៃអំពើប្រល័យពូជសាសន៍ និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេង។ទៀត មិនត្រូវបានលើកយកមកពិភាក្សាឲ្យបានទូលំទូលាយនៅក្នុងវគ្គបណ្តុះបណ្តាលនេះឡើយ ។ តើអ្វីទៅជាផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ មកលើសង្គមកម្ពុជានាពេលបច្ចុប្បន្ន? តើអ្វីទៅជាស្ថានភាពដែលនាំទៅដល់ការកើតមានឡើងនៃអំពើប្រល័យពូជសាសន៍? ហេតុអ្វីបានជាមេដឹកនាំជ្រើសរើសក្មេងជំទង់មកបម្រើការងារ? ហេតុអ្វីបានជាមនុស្សធ្វើការកំណត់ក្រុមមនុស្ស? ហេតុអ្វីបានជាមនុស្សសម្លាប់មនុស្ស?*

***អនុសាសន៍*** *: យើងគួរបញ្ចូលសំណួរប្រភេទនេះ ទៅក្នុងការអនុវត្តន៍មេរៀនគំរូនិងការពិភាក្សាទាំងអស់ ហើយបញ្ជាក់ប្រាប់គ្រូបង្គោលថ្នាក់ជាតិថា ទាំងនេះគឺជាសំណួរចម្បង ហើយប្រហែលជាមានសារៈសំខាន់ជាង ក្នុងការសួរទៅសិស្ស ។ ទោះបីជាថ្ងៃខែនិងការពិតមានសារៈសំខាន់យ៉ាងណាក៏ដោយ គ្រូត្រូវតែពង្រឹងបញ្ហានេះនៅក្នុងថ្នាក់រៀនទាំងអស់ ។ អនុសាសន៍មួយទៀតគឺថា យើងរង់ចាំអនុវត្តទៅលើគោលរឿងសិននៅក្នុងវគ្គបណ្តុះបណ្តាលលើកទីពីរនិងលើកក្រោយ។ទៀត ដោយផ្តោតទៅលើការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលប្រវត្តិសាស្ត្រជាមូលដ្ឋានត្រូវបានសិក្សាហើយគ្រូយល់ដឹងនិងអាចបង្រៀនចំណេះដឹងបឋម យើងអាចបន្តទៅការសិក្សាបែបទ្រឹស្តីនិងទស្សនវិជ្ជា ។*

***៦. ភាពគ្មានតឹងពីគ្រូបង្គោលថ្នាក់ជាតិ*** *: វាហាក់ដូចជាមានភាពគ្មានតឹងមួយចំនួននៅក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល ។ បញ្ហាមួយអាចថា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមានវ័យក្មេងជាងគ្រូបង្គោលថ្នាក់ជាតិ ។ ភាពគ្មានតឹងក៏អាចបណ្តាលមកពីបញ្ហាដែលថា គ្រូបង្គោលថ្នាក់ជាតិមិនមានអារម្មណ៍ថា ខ្លួនជាម្ចាស់លើគម្រោងនេះ ។ គ្រូបង្គោលថ្នាក់ជាតិមួយចំនួនបានស្នើសុំឲ្យដកឈ្មោះរបស់ខ្លួនចេញពីសៀវភៅណែនាំគ្រូ ។*

***អនុសាសន៍ ៖*** *ដើម្បីសម្រាលបញ្ហានេះ យើងគួរអញ្ជើញអ្នកបណ្តុះបណ្តាលដែលមានវ័យចំណាស់ច្រើន ជាងនេះ ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើកក្រោយ ។ យើងក៏គួរបញ្ជាក់ដែរថា សៀវភៅណែនាំគ្រូ គ្រាន់តែជាមគ្គុទ្ទេសក៍ប៉ុណ្ណោះ ហើយគ្រូបង្គោលថ្នាក់ជាតិមានសេរីភាពគ្រប់គ្រាន់ក្នុងការងាកចេញពីសៀវភៅនេះ ។ ជាងនេះទៅទៀត យើងក៏អាចពន្យល់ថា ការចូលរួមរបស់គ្រូបង្គោលថ្នាក់ជាតិទាំងអស់មានតម្លៃខ្លាំងណាស់ចំពោះគម្រោង ហើយយើងត្រូវការគ្រូបង្គោលថ្នាក់ជាតិទាំងអស់ ដើម្បីធានាឲ្យបានជោគជ័យ ។ លោក ឌី ខាំបូលី បានសហការយ៉ាងល្អ ក្នុងការនិយាយប្រកបដោយការទូតនិងការគោរពទៅកាន់គ្រូបង្គោលថ្នាក់ជាតិទាំងអស់ ហើយយើងគួរតែបន្តប្រើប្រាស់ការនិយាយស្ដីនិងឥរិយាបទបែបនេះទៀត ។ ជាចុងក្រោយ ភាពជាអ្នកដឹកនាំត្រូវពង្រឹងក្នុងចំណោមអ្នកសម្របសម្រួល ដើម្បីនាំយកការពិភាក្សាឲ្យស្ថិតនៅលើគោលដៅ ជាជាងងាកចេញពីគោលបំណងនៃវគ្គសិក្សា ។*

## ***៧. គ្រូបង្គោលថ្នាក់ជាតិផ្តោតការចាប់អារម្មណ៍ទៅលើកិច្ចការរដ្ឋបាល ជាជាងគោលបំណងធំៈ***

*ការទទួលខុសត្រូវនិងកិច្ចការផ្នែករដ្ឋបាល ហាក់ដូចជាមានអាទិភាពនៅក្នុងថ្នាក់រៀន ។ គ្រូបង្គោលថ្នាក់ជាតិមានការតឹងតែងចំពោះគ្រូទាំងឡាយណា ដែលមិនបានដាក់ថ្ងៃខែនៅលើក្តារខៀន ឬដែលមិនអនុវត្តតាមគោលការណ៍៥ជំហានដែលខ្លួនបានរៀន ។ គ្រូបង្គោលថ្នាក់ជាតិមួយចំនួន បង្រៀនមេរៀនដោយផ្តោតទៅលើការនិយាយតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្របឋម ។ មេរៀនទាំងនេះស្ថិតនៅជុំវិញតែបញ្ហាដែលគ្រូសួរសំណួរ ហើយចម្លើយមាន«ពិត»ឬ«មិនពិត» ឬជាការបកស្រាយខ្លីៗ ។ គ្រូមួយចំនួនចោទសួរនូវសំណួរពិបាកៗ ប៉ុន្តែភ្លាមៗបានឆ្លើយនូវចម្លើយដោយខ្លួនឯង ។ ជាទូទៅ គ្រូដាក់ឲ្យអនុវត្តនូវគំនិត«ត្រូវ»ឬ«ខុស»របស់ខ្លួន ហើយមិនមានអារម្មណ៍ល្អទេ ក្នុងការអនុញ្ញាតឲ្យសិស្សពិភាក្សាទៅលើទស្សនរបស់ខ្លួន ។ គ្រូបង្គោលថ្នាក់ជាតិមួយចំនួនយល់អំពីវិធីសាស្ត្របង្រៀនមូលដ្ឋាន នៅក្នុងមេរៀននីមួយៗ (ឧទាហរណ៍ អ្វីដែលត្រូវបានបង្រៀន ជាជាងអ្វីដែលបានរៀន ។ ហេតុអ្វីបានជាត្រូវបង្រៀនដូច្នេះ? និងថាតើមេរៀននេះត្រូវបានបង្រៀនដោយរបៀបណា?) ប៉ុន្តែគ្រូ បង្គោលថ្នាក់ជាតិមិនទទួលបានការអនុវត្តគ្រប់គ្រាន់ទៅលើវិធីសាស្ត្របង្រៀនផ្សេងៗ ដើម្បីអាចប្រើប្រាស់មេរៀនឲ្យមានប្រសិទ្ធភាព ។*

***អនុសាសន៍ ៖*** *យើងត្រូវតែផ្តល់ពេលវេលាបន្ថែមទៅលើការអនុវត្តន៍មេរៀន ដើម្បីឲ្យគ្រូបង្គោលថ្នាក់ជាតិមានជំនាញគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលគ្រូបន្ត ។ អ្នកសម្របសម្រួលនៅក្នុងក្រុមតូចៗគួរចាប់អារម្មណ៍អំពីសារៈសំខាន់នៃព័ត៌មានលម្អិតទាំងនេះ នៅក្នុងវិធីសាស្ត្របង្រៀនបែបខ្មែរ ។ ប៉ុន្តែអ្នកសម្របសម្រួលក៏ត្រូវព្យាយាមបង្កើតឲ្យមានការពិភាក្សា និងការផ្តល់យោបល់កែលម្អទៅលើមេរៀន ។*

ខាងក្រោម ជាអនុសាសន៍មួយចំនួនទៀតដែលត្រូវបានលើកឡើង ៖

១. មិនគួរធ្វើការផ្លាស់ប្តូរច្រើនទេ ទៅលើកម្មវិធីរបស់គ្រូបង្គោលថ្នាក់ជាតិនិងអ្នកជំនាញអន្តរជាតិ ។ ការប្រជុំក្រោយវគ្គបណ្តុះបណ្តាលនិងអាហារពេលល្ងាច គួរត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធី ដើម្បីឲ្យគ្រូបង្គោលថ្នាក់ជាតិនិងអ្នកជំនាញអន្តរជាតិទាំងអស់ អាចរៀបចំផែនការបានល្អ ។

២. ត្រូវមានប្រព័ន្ធអ៊ិនធឺណែតនៅក្នុងបន្ទប់បណ្តុះបណ្តាល ។

៣. ត្រូវរៀបចំកញ្ចប់ធំមួយជូនដល់គ្រូបង្គោលថ្នាក់ជាតិ ដែលរួមមានផែនទីកម្ពុជាប្រជាធិបតេយ្យ សន្ទានុក្រម សៀវភៅរូបភាព ឌីវីឌី និងសម្ភារៈផ្សេងៗទៀត ។

៤. ត្រូវដាក់ចំណងជើងរូបថតឲ្យបានច្បាស់លាស់ ឬយើងត្រូវស្វែងរកវិធីដែលគ្រូអាចឆ្លើយទៅនឹងសំណួរដែលសិស្សលើកឡើងទាក់ទងនឹងរូបភាព ប្រសិនបើគ្រូមិនអាចពណ៌នាបាន ។

៥. គួរផ្តល់ប័ណ្ណឈ្មោះពណ៌ ដល់គ្រូបង្គោលថ្នាក់ជាតិទាំងអស់ ហើយក្រុមត្រូវបានបែងចែករួចជាស្រេច មុនវគ្គបណ្តុះបណ្តាលចាប់ផ្តើម ។

៦. គ្រូបង្គោលថ្នាក់ជាតិទាំងអស់គួរជួបប្រជុំគ្នា មុនពេលរៀបចំវគ្គបណ្តុះបណ្តាលលើកក្រោយ ដើម្បីពិនិត្យមើលទៅលើសម្ភារៈសម្រាប់បណ្តុះបណ្តាលទាំងអស់គ្នា ។

៧. អត្ថបទអានសម្រាប់វគ្គបណ្តុះបណ្តាល គួរតែរៀបចំទៅតាមលំដាប់លំដោយនៃបទបង្ហាញ ដោយមានដាក់លេខទំព័រ និងកាលបរិច្ឆេទនៃការធ្វើបទបង្ហាញ ។ ប្រការនេះនឹងអាចឲ្យគ្រូបង្គោលថ្នាក់ជាតិដឹងថា តើវាគ្មិនឡើងធ្វើបទបង្ហាញទៅលើអត្ថបទមួយណា ហើយគ្រូបង្គោលថ្នាក់ជាតិគួរអានអត្ថបទណានៅថ្ងៃណា ។

៨. អត្ថបទសម្រាប់ថ្ងៃទីមួយគួរតែដកចេញ ឬគ្រូបង្គោលថ្នាក់ជាតិត្រូវអានអត្ថបទទាំងនេះមុនវគ្គបណ្តុះបណ្តាលចាប់ផ្តើម ។ យើងក៏អាចប្តូរអត្ថបទទាំងនេះទៅថ្ងៃផ្សេងដែរ ។

៩. ត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់គ្រូបង្គោលថ្នាក់ជាតិ ដើម្បីសួរនិងឆ្លើយទៅនឹងសំណួរ ។ អ្នករៀបចំវគ្គបណ្តុះបណ្តាលគួររៀបចំឲ្យមានការសួរសំណួរពី១៥ទៅ៣០នាទី សម្រាប់បទបង្ហាញនីមួយៗ ។

១០. សន្ទានុក្រមនៃពាក្យគន្លឹះនៅក្នុងអត្ថបទ គួរត្រូវបានចែកជូនដល់អ្នកបកប្រែនិងគ្រូបង្គោលថ្នាក់ជាតិទាំងអស់ ដើម្បីជៀសវាងការភ័ន្តច្រឡំទៅលើការប្រើប្រាស់ពាក្យពិបាក ។

១១. ការប្រជុំរវាងអ្នកសម្របសម្រួលមុនការបណ្តុះបណ្តាល គួរត្រូវបានធ្វើឡើងដើម្បីកំណត់ថា ៖ តើមេរៀនមួយណាគួរធ្វើជាមេរៀនគំរូ? តើការអនុវត្តមេរៀនរបស់ក្រុមតូចៗត្រូវធ្វើឡើងដោយរបៀបណា? តើវិធីសាស្ត្រណានឹងត្រូវបានលើកយកមកបង្រៀនឬពន្យល់?

## ៨. សេចក្តីសន្និដ្ឋាន

បីទសវត្សរ៍បានកន្លងផុតទៅហើយ ចាប់តាំងពីពិភពលោកបានសិក្សាអំពី«វាលពិឃាត» នៅកម្ពុជា ដែលរួមមានទារុណកម្មជាលក្ខណៈប្រព័ន្ធ ការសម្លាប់ក្នុងទ្រង់ទ្រាយធំ ការស្លាប់រាប់មិនអស់ ដោយសារការអត់អាហារ ។ នៅក្នុងរយៈពេលបីទសវត្សន៍នេះដែរ ការអប់រំអំពីរយៈកាលដ៏ឃោរឃៅនេះ មិនទាន់ត្រូវបានអនុវត្តនៅក្នុងថ្នាក់រៀនឲ្យបានទូលំទូលាយនៅឡើយទេ ។ ដូចដែលយើងបានដកស្រង់សម្តីរបស់លោកគ្រូម្នាក់ ដែលបានថ្លែងថា«ខ្ញុំបានរង់ចាំការអប់រំអំពីរបបនេះអស់រយៈពេល៣០ឆ្នាំមកហើយ» ។

បញ្ហានយោបាយ ជានិច្ចកាលមានឥទ្ធិពលទៅលើរបៀបដែលប្រព័ន្ធអប់រំបកស្រាយ ឬកំណត់ព្រឹត្តិការណ៍ប្រវត្តិសាស្រ្តសំខាន់ៗ ។ ជួនកាល ប្រវត្តិសាស្រ្តខ្មែរក្រហមត្រូវបានប្រើប្រាស់ជាយុទ្ធនាការឃោសនានៅក្នុងកម្មវិធីសិក្សារបស់សាលា ។ នៅក្នុងករណីខ្លះទៀត រយៈកាលនៃរបបនេះ មិនត្រូវបានលើកយកមកសិក្សានៅក្នុងថ្នាក់រៀនទេ ។ ទោះជាយ៉ាងនេះក្តី កិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡា ទៅលើគម្រោងស្តីពីការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ គឺជាដំណើរការលើកដំបូង ក្នុងការដាក់ឲ្យមានការសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ ប្រកបដោយការពិតឥតលម្អៀង ។ ទោះបីជាគម្រោងនេះមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយក៏ដោយ ក៏នេះគឺជាចំណុចចាប់ផ្តើមដ៏ល្អមួយក្នុងការផ្តល់ឲ្យប្រជាជនកម្ពុជានូវឧបករណ៍និងប្រភពធនធាន ដើម្បីស្វែងយល់និងសិក្សាពីប្រវត្តិសាស្រ្តរបស់ខ្លួនដែរ ។ ការយល់ដឹងតាមរយៈការអប់រំ គឺជាជំហានដ៏មានសារៈសំខាន់មួយក្នុងការទប់ស្កាត់កុំឲ្យអំពើនេះកើតមានឡើងសាជាថ្មី ។ កូនចៅជំនាន់ក្រោយត្រូវទទួលបានការអប់រំ ដើម្បីយល់ដឹងថា តើត្រូវក្រោកឈរឡើងប្រឆាំងនឹងអំពើយង់ឃ្នងនៅពេលណា? ។

**ចប់**